មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយ ភោក មឿន ភេទ ស្រី អាយុ៥៧ ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ "កងចល័ត"

## មានស្រុកកំណើត នៅភូមិ នៅភូមិរកាជួរ ឃុំខ្វែង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

## សព្វថ្ងៃរស់នៅភូមិសែនសុខ ឃុំទ្រនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឌី ខាំបូលី

## ០១:១៥:២៣

## ៤៦ ទំព័រ

បូលី : ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣ ។ មីងឈ្មោះអីគេមីង?

មឿន : ឈ្មោះ ភោក មឿន ។

បូលី : សព្វថ្ងៃនេះអាយុប៉ុន្មានហើយ?

មឿន : អាយុ ៥៧ ។

បូលី : មីងមានធ្វើការអីទេ រាល់ថ្ងៃ ឬក៏ប្រជាជនទេ?

មឿន : ប្រជាជន ។ ឈប់ធ្វើអស់ហើយ ។

បូលី : ពីមុនអត់មានធ្វើការ ភូមិ ឃុំអីទេ?

មឿន : កាលមុនខ្ញុំធ្វើប្រធានភូមិ ។ ដល់ពេលទៅ ឲ្យគេធ្វើម្ដង ខ្ញុំឈប់ទៅ ។

បូលី : អ៊ូ! អញ្ចឹងមីងធ្វើមេភូមិហ្នឹង មុនពូទៀត?

មឿន : ចាស៎!

បូលី : បាទ! ហើយមីងមានស្រុកកំណើតអីនៅណាដែរ?

មឿន : នៅកំពង់ធំ នៅស្រុកសណ្ដាន់ ។

បូលី : ភូមិ ឃុំ អីគេ?

មឿន : ឃុំខ្វែង ស្រុកសណ្ដាន់ ។

បូលី : ចុះភូមិ?

មឿន : ភូមិរកាជួរ ។

បូលី : មីងអ្នកកំពង់ធំ?

មឿន : កំពង់ធំ ។

បូលី : ហើយបច្ចុប្បន្ននេះ អាស្រ័យដ្ឋាន ភូមិ ឃុំ អីគេ បច្ចុប្បន្ន?

មឿន : ភូមិសែនសុខ ឃុំទ្រនប់ដាច់ ស្រុកត្រពាំងប្រាសាទ ។

បូលី ៖ បាទ! ម៉េចបានជាគេដាក់ឈ្មោះភូមិសែនសុខ?
មឿន ៖ មិនដឹង! គេដាក់តាំងពីអើយមក ។
បូលី ៖ ឈ្មោះហ្នឹងគេដាក់តាំងពីដើមមក ឬក៏យ៉ាងម៉េច?
មឿន ៖ ទើបតែដាក់ហ្នឹងឯង ។
បូលី ៖ ម៉េចបានគេហៅ សែនសុខ មីងមានដឹងទេ ក្នុងឋានៈមីងជាមេភូមិ?
មឿន ៖ ចុះ! នៅយូៗទៅវាសុខ វាគ្មានកើតស្អី ។
បូលី ៖ ម៉េចក៏មិនដាក់សុខ ទទេទៅ មិនចាំបាច់មានសែន?
មឿន ៖ សើច! មិនដឹងគេដាក់ ។
បូលី ៖ បាទ! ហើយកូនចៅប៉ុន្មានហើយ រាល់ថ្ងៃនេះមីង?
មឿន ៖ ខ្ញុំ ៥នាក់ ។ ស្រី១នាក់ ៤នាក់ ។
បូលី ៖ ស្រីតែម្នាក់ទេ?
មឿន ៖ ចាស!
បូលី ៖ ហើយរៀបបានប៉ុន្មាន នៅប៉ុន្មាន?
មឿន ៖ ការរួចអស់ហើយ ។
បូលី ៖ អស់ហើយ?
មឿន ៖ ចាស!
បូលី ៖ អញ្ចឹងរាល់ថ្ងៃនៅតែពីរនាក់យាយតាទេ?
មឿន ៖ នៅតែពីរនាក់យាយតា ។ ទៅនៅជាមួយកូនពៅ ។
បូលី ៖ បាទ! កូនពៅនៅជាមួយ?
មឿន ៖ ចាស!
បូលី ៖ កូនពៅហ្នឹង ស្រី ឬប្រុស?
មឿន ៖ ស្រី ។
បូលី ៖ បាទ! ខ្ញុំចង់សួរបកទៅក្រោយបន្តិច មីងចូលបដិវត្តន៍តាំងពីឆ្នាំណាមក?
មឿន ៖ ខ្ញុំហ្នឹង?
បូលី ៖ បាទ!
មឿន ៖ តាំងពី៧៩ ។
បូលី ៖ ៧៩?
មឿន ៖ ចាស!

បូលី ៖ ចុះមិនមែនចូលតាំងពីរដ្ឋប្រហារសម្ដេចឪឆ្នាំ៧០ទេ?

មឿន ៖ កាលហ្នឹងនៅភូមិហ្នឹងឯង ។

បូលី ៖ កាលហ្នឹងនៅហ្នឹង?

មឿន ៖ ចាស! នៅស្រុកសណ្ដាន់ ។

បូលី ៖ ពី៧៥ ទៅ៧៩ មីងនៅណា?

មឿន ៖ ៧៥ ខ្ញុំនៅផ្ទះ នៅកងចល័ត ។

បូលី ៖ សម័យខ្មែរក្រហម?

មឿន ៖ ចាស! នៅកងចល័ត ។

បូលី ៖ កងចល័តអីគេ?

មឿន ៖ កងចល័តឃុំ ។

បូលី ៖ ឃុំរបស់មីងហ្នឹង?

មឿន ៖ ចាស!

បូលី ៖ មីងធ្វើអីគេ ធ្វើប្រធានកងចល័ត ឬក៏គ្រាន់តែជាសមាជិកកងចល័ត?

មឿន ៖ អត់ធ្វើអីទេ!

បូលី ៖ ធ្វើតែសមាជិកគេហ្នឹងទៅ?

មឿន ៖ ចាស! ធ្វើសមាជិកគេ ។

បូលី ៖ ពីណាគេប្រធានកងចល័តពេលហ្នឹង?

មឿន ៖ ប្រធានគេនៅឆ្ងាយណាស់ ។ គេយកប្ដីសីទៅណា៎ បែកគ្នាអស់រលីងហើយ ។

បូលី ៖ អញ្ចឹង! នៅណាឆ្ងាយហ្នឹង ទៅនៅដល់ណា?

មឿន ៖ គេនៅភូមិហ្នឹងឯង ប៉ុនគេយកប្ដី គេទៅនៅតាមប្ដីគេអស់ទៅ ។

បូលី ៖ គេនៅហ្នឹងដែរ?

មឿន ៖ អត់ទេ! នៅស្រុក ។

បូលី ៖ អ្ហូ! នៅស្រុកសណ្ដាន់ ។

មឿន ៖ ចាស!

បូលី ៖ សព្វថ្ងៃដែលជួប និយាយគ្នាលេងទេ?

មឿន ៖ អត់ដែលជួបទេ តាំងពីខ្ញុំបែកពីគេមក ។

បូលី ៖ អញ្ចឹងពី៧៥ មក៧៩ មីងនៅតែកងចល័តហ្នឹងរហូត?

មឿន ៖ ចាស! នៅរហូតដល់ពេល៧៩ គេថាយួនចូលស្រុកៗហ្នឹង ក៏រត់តាមគេបណ្ដោយទៅ ។

បូលី ៖ អ៊ូ! ហើយការងារកងចល័តហ្នឹងគេឲ្យធ្វើអីខ្លះ?
មឿន ៖ លើកទំនប់ ជីកប្រឡាយ លើកភ្លឺស្រែអីហ្នឹង ។
បូលី ៖ តែប៉ុនហ្នឹងទេ?
មឿន ៖ ចា៎ស!
បូលី ៖ អត់មានដាំស្រូវ ដាំចម្ការអីទេ?
មឿន ៖ ទេ! ស្រូវ ដូចថាកងចល័ត ភូមិណាគេស្នើទៅ ទៅជួយតែម្ដង គេថាកងចល័តៗ ចល័តទៅភូមិនេះ ភូមិនោះ ។
បូលី ៖ ចល័តបានន័យថា យើងដូរពីទីតាំងមួយ ទៅទីតាំងមួយទៀត ។
មឿន ៖ ចា៎ស! ដូចថាភូមិណាគេស្នើថាជួយវៃសម្រុកស្រូវ គេច្រើនអញ្ចឹងទៅ យើងទៅហើយ ជួយច្រូត ជួយស្ទូងគេ ។
បូលី ៖ កាលហ្នឹងគេថាយើងវៃសម្រុកអញ្ចឹងតែម្ដងមីង?
មឿន ៖ ចា៎ស! ដូចត្រូវជួយភូមិណាឲ្យរួច ទៅហ្នឹងហើយ លើកប្រឡាយ លើកទំនប់ហ្នឹងឯង ។
បូលី ៖ ស្រុកសណ្ដាន់ ពីណាគេគណៈស្រុកកាលហ្នឹងមីង?
មឿន ៖ កាលមុនស្រុក តាកន ។
បូលី ៖ តាកន គណៈស្រុក?
មឿន ៖ ចា៎ស! តាកន មក តាសុខ ។
បូលី ៖ តាកន ទៅណា?
មឿន ៖ មិនដឹងទៅណាទៅណីទេ បែកគ្នាអស់រលីងហើយ ។
បូលី ៖ តាសុខ ហ្នឹងអនុរបស់ តាកន ឬក៏គេដកតាកន ហើយដាក់តាសុខ?
មឿន ៖ ដាក់តាសុខ ។
បូលី ៖ ដកតាកន ចេញ?
មឿន ៖ អេ៎! តាសុខ មុនមិនដឹង! តាសុខ មុន ឬក៏តាកន មុនទេដូចវៀងស្រពិចស្រពិល ។
បូលី ៖ អញ្ចឹង!
មឿន ៖ ចា៎ស! ស្រុកសណ្ដាន់ ។
បូលី ៖ ពូ អ្នកសណ្ដាន់ដែរ?
មឿន ៖ សណ្ដាន់ដែរ ប៉ុនគាត់ចូលមុនខ្ញុំ ។
បូលី ៖ ពូ ហើយនឹងមីងការឆ្នាំប៉ុន្មាន?
មឿន ៖ យកគ្នាតាំងពីឆ្នាំ៨០ ។

បូលី ៖ ក្រោយ ៧៩ ទេអញ្ចឹង?

មឿន ៖ ចា៎ស! ៧៩ ខ្ញុំនៅរត់នៅឡើយហ្នឹង ។

បូលី ៖ ស្មានតែយកតាំងពីអាពត ពីសម័យខ្មែរក្រហម ។

មឿន ៖ ទេ! រត់ទៅ រត់ចុះ រត់ឡើងហ្នឹង បានគ្នាលើភ្នំ ។ ចា៎ស! ខ្ញុំនៅនេះ មិនដែលឃើញគាត់ផង ។

បូលី ៖ ចុះពេលដែលគេថា យួនវៃចូលហ្នឹង រត់តាមណាមក?

មឿន ៖ រត់តាមគេ! គេចេះតែនាំមក ចេះតែទៅតាមគេទៅ ។

បូលី ៖ កាលហ្នឹងមីង ឮសូរគេដូចម្ដេច?

មឿន ៖ គេថា យួនកាត់ក កាត់អីណាណីចេះតែខ្លាចទៅ ។

បូលី ៖ គេឃោសនាអញ្ចឹង?

មឿន ៖ ចា៎ស!

បូលី ៖ ឃោសនាថា យួនកាត់ក?

មឿន ៖ ចា៎ស! ហើយខ្ញុំចេះតែរត់តាមគេទៅ ។

បូលី ៖ អញ្ចឹងយើងចេះតែរត់តាមគេ?

មឿន ៖ ចា៎ស! រត់តាមគេ រត់ដល់លើភ្នំ ។

បូលី ៖ កាលរត់ហ្នឹង រត់ប៉ុន្មាននាក់ កាលហ្នឹង?

មឿន ៖ ច្រើនណាស់! មិនដឹងខាងណាខាងណីមកជុំគ្នា ។

បូលី ៖ មកតែកងចល័ត តែទាហាន តែកម្មាភិបាលខ្មែរក្រហម ឬក៏ទាំងប្រជាជនដែរ?

មឿន ៖ ប្រជាជន មិនមកពីខាងណា មកពីកំពង់ចាម មកចម្រុះ ជម្លៀសមួយសារនោះវាច្របូកច្របល់គ្នានោះ ៧៩ មិនថាយួនចូល ។

បូលី ៖ បាទ! យួនចូល ។

មឿន ៖ ហើយក៏ច្របូកច្របល់ អានៅភូមិក៏ចេញ អាអ្នកមកពីកំពង់ចាម មកពីព្រំដែនក៏គេចូលមកភូមិវិញ ឯងនេះក៏ចេញពីភូមិវិញ រត់តាមគេគាត់តែឯៗ ទៅណា៎! ។

បូលី ៖ នេះមីងនៅម្តុំនេះ ស្រុកសណ្ដាន់ ដែលមីងនៅនោះណា៎!(បងបូលីបង្ហាញពីផែនទីភូមិសាស្រ្តប្រាប់ទៅមីង មឿន) ។ ហើយនេះ ១០០១, ១០០៣ ភ្នំ១០០៣ ដែលមីងថាច្រក១០០៣មិញហ្នឹងណា៎ ហើយនេះសណ្ដាន់ អញ្ចឹងពេលដែលយួនវៃយូលមកមីងរត់តាមណា៎ មកដល់លើភ្នំហ្នឹង?

មឿន ៖ ចាំមើល៉! ចេញពីភូមិខ្ញុំមក មកតាមកន្លែងទីរួមស្រុកៗ ចេញពីស្រុកមកឆ្លងស្ទឹងសែនហ្នឹង កាត់ព្រៃបណ្ដោយ ។

បូលី ៖ កាត់ព្រៃ?

មឿន ៖ ចា៎ស!

បូលី ៖ កាត់តាមព្រះវិហារ,

មឿន ៖ មិនដឹងខាងណាទេ! កាត់តាមព្រៃរហូត ទៅដល់ភូមិរំដួលអំពិលនោះ ។

បូលី ៖ មីងចេញពីសណ្ដាន់មក មកព្រំដែននេះមកម្ដុំណា៎ មក១០០១ ឬមក១០០៣?

មឿន ៖ អត់ទេ! សៀវនោះទៅលិចវិញនោះ ។

បូលី ៖ អញ្ចឹងទេ?

មឿន ៖ ចា៎ស!

បូលី ៖ មកខាងណាវិញ លិចហ្នឹងខាងណា?

មឿន ៖ មកដល់ភូមិរំដួលៗអំពិល ខេត្តឧត្តរមានជ័យ ។

បូលី ៖ ខេត្តឧត្តរមានជ័យ?

មឿន ៖ ចា៎ស!

បូលី ៖ អញ្ចឹងនៅស្រុកបន្ទាយអំពិល?

មឿន ៖ ចា៎ស! មកដល់ភូមិរំដួលហ្នឹង គេកាក់ឲ្យពួកខ្ញុំនៅហ្នឹង ។

បូលី ៖ ពីណាគេកាក់មីង?

មឿន ៖ ខាងខេត្តឧត្តរមានជ័យ ហ្នឹងឯង! គណៈភូមិភាគគេឃាត់ស្រីៗអីនៅហ្នឹង ពួកខ្ញុំនៅហ្នឹង ។

បូលី ៖ ខាងខ្មែរក្រហម?

មឿន ៖ ចា៎ស! គេឃាត់ឲ្យនៅហ្នឹងទៅ ខ្ញុំនៅហ្នឹងទៅ ។ បន្ទាប់ពីថា យួនវ៉ៃវា រត់ឡើងភ្នំ បណ្ដោយ ។

បូលី ៖ រត់ឡើងទៅម្ដុំណា?

មឿន ៖ រត់ទៅម្ដុំភ្នំស្នាច់ ហួសស្នាច់ហ្នឹងទៀត ។

បូលី ៖ អូស្នាច់?

មឿន ៖ ចា៎ស! អណ្ដែងមុតៗ ស្គាល់អណ្ដែងមុត ហើយនឹងភូមិស្អីគេហៅ ភូមិបៃឆ្អែ លិចទៀត នោះ ស្គាល់ទេ? ខ្ញុំទៅដល់ហ្នឹងឯង ។

បូលី ៖ អ៊ូ! មកមួយចំនៀខាងលិចហើយហ្នឹង?

មឿន ៖ ចាស៎! ឡើងភ្នំហ្នឹងទៅ បានមកដូរៗរហូត មកដល់នេះ មកដល់១០០២, ១០០១, ១០០៣ ។

បូលី ៖ ពីណាគេជាអ្នកនាំមីងរត់កាលហ្នឹង?

មឿន ៖ កាលហ្នឹង ដូចខ្ញុំថាអញ្ចឹង ចេះតែរត់តាមគ្នាទៅ ខ្លាចចេះតែទៅតាមគេទៅ ។

បូលី ៖ ទៅតាមគេ?

មឿន ៖ ចា៎ស! គេប្រមាថវ៉ៃចោលតាមផ្លូវក៏ឃើញ ។

បូលី ៖ រត់ហ្នឹងយើងដើរតែម្តង?

មឿន ៖ ដើរ!

បូលី ៖ កាត់ព្រៃមក?

មឿន ៖ ចា៎ស! កាត់ព្រៃ អស់អង្ករចូលភូមិៗ ។

បូលី ៖ អស់អង្ករចូលភូមិ?

មឿន ៖ ចា៎ស! ចូលភូមិសុំគេ ច្រកពេញថៃ ដើរទៅទៀត ។

បូលី ៖ បាទ! អ្នកភូមិគេឲ្យដែរ?

មឿន ៖ ឲ្យ!

បូលី ៖ គេអត់ខឹងសម្បារអីខាងយើង?

មឿន ៖ គេនេះដែរហ្នឹង តែប្រយ័ត្ន ខ្ញុំប៉ិះគេកាប់មួយដងហើយ អត់ដឹង ។

បូលី ៖ អញ្ចឹង?

មឿន ៖ ចា៎ស! ចូលទៅដល់ប្អុក ស្រែកទឹកពេក ឃើញអណ្តូងទឹក ណែ៎!មកដល់ភូមិស្អីនេះ ដល់ពេល ពូៗប្រាប់ដែរថា បងនារី បើចូលភូមិមួយៗយ៉ាងណាក៏ដោយ កុំឲ្យប្រហែស ប្រយ័ត្នគេកាប់ប្រជាជនកាប់ ខ្ញុំឃើញស្រែកទឹកពេក ទៅដល់ចូលអណ្តូងប្អុក! លីខ្មែរមក ឡើងស្រូ កុំតែបានកាំភ្លើងប្រូងមកងាប់មួយសារនោះបាត់ទៅហើយ ។

បូលី ៖ ខាងយើងមានកាំភ្លើង?

មឿន ៖ ចា៎ស!

បូលី ៖ ខាងគេមានខ្មែរ?

មឿន ៖ កាំបិតខ្មែរប្រជាជន ដេញកាប់ ។

បូលី ៖ មានអ្នកធ្លាប់ត្រូវគេកាប់ស្លាប់អីទេ?

មឿន ៖ មានស្លាប់ដែរហ្នឹង ។

បូលី ៖ ដែលចូលទៅសុំអង្ករហ្នឹង?

មឿន ៖ ចា៎ស!

បូលី ៖ ចុះបើសុំគេមិនឲ្យធ្វើយ៉ាងម៉េចទៅ?

មឿន ៖ ទៅទៀតទៅ ។

បូលី ៖ យើងអត់ក្រឆក់យកអី?

មឿន ៖ ទេ!ទៅទៀតទៅ ចូលមិនបានទៅទៀត ។

បូលី ៖ ព្រោះកាលហ្នឹងក៏អត់ ហើយខាងនោះក៏មិនសូវជាសបូរប៉ុន្មានដែរឆ្នាំ៧៩នោះ ។

មឿន ៖ វាច្របូកច្របល់គ្នា មិនដឹងណាណីទេ ។

បូលី ៖ ក្រទាំងអស់គ្នា កាលហ្នឹង ។ ហើយតាំងពីសណ្ដាន់ហ្នឹង រហូតមកដល់ទល់ដែនហ្នឹង ដើរប្រហែលប៉ុន្មានខែ ប៉ុន្មានថ្ងៃឆ្លងកាត់ភូមិឃុំ?

មឿន ៖ ច្រើនខែដែរហ្នឹង ។

បូលី ៖ ប្រហែលប៉ុន្មានខែ?

មឿន ៖ ច្រើនដែរ (៣-៤ ខែដែរហ្នឹង) ។

បូលី ៖ ហើយមីងថាមកព្រំដែនហ្នឹង ចៃឆ្កែអីហ្នឹងនៅក្នុងស្រុកអីទៅ?

មឿន ៖ ខាងបាត់ដំបង ខាងអីហ្នឹងដឹង មើល៎ៗភ្នំខាងណាខាងហ្នឹង ។

បូលី ៖ ម៉ាល័យ?

មឿន ៖ បើមិនម៉ាល័យ ក៏ស្អីហ្នឹងឯង ។

បូលី ៖ មានម៉ាល័យ, សំពៅលូន, កំរៀង, ភ្នំព្រឹក, សំឡូត, ប៉ៃលិន ម្ដុំណាតាមមីងគិតមើល?

មឿន ៖ មិនដឹងម្ដុំត្រង់ណា ខ្ញុំអត់ដែលឃើញទេ ប៉ៃលិន នោះហ្នឹង ។ មានប្រជាជនណានៅ ទើបតែឥឡូវទេ មានប្រជាជននៅនោះ មុនអត់មានទេ ។

បូលី ៖ មីងថា ភ្នំអីគេមិញ ភ្នំចៃឆ្កែ?

មឿន ៖ ចា៎ស! ចៃឆ្កែ ខាងលិចនោះ ។ ខាងលិចរំដួលទៀត ខាងលិចអណ្ដែងមុតទៀត ។

បូលី ៖ មកម្ដុំអូរស្នាច់ទៀត?

មឿន ៖ ចា៎ស!

បូលី ៖ អូរស្នាច់មក ថ្មដូន, មកជប់អូរគី មករំដួលៗហ្នឹងនៅក្នុងស្រុកបន្ទាយអំពិល ។

មឿន ៖ ខ្ញុំនៅត្រឹមរំដួលហ្នឹងឯងប៉ុនខ្ញុំឡើងលើភ្នំ ។

បូលី ៖ រំដួលវាមានដងរ៉ាក់ ។ ស្គាល់ទេមីងដងរ៉ាក់ គោកព្រីកអី?

មឿន ៖ ទេ ខ្ញុំឮតែគេថា ខ្ញុំគោកមនអីនោះ ខ្ញុំនៅលើភ្នំ ចុះមកធ្វើស្រែនៅសាយរាក់ ថ្មល់ធំ ។ ភូមិសាយរាក់ធ្វើស្រែហ្នឹង ទាហានដេញរត់ឡើងភ្នំទៀត ។

បូលី :	ដូចអត់មានទេ ឈ្មោះបៃផ្លែអីហ្នឹងនោះ ។
មឿន :	ភូមិបៃផ្អែអត់មានទេ?
បូលី :	អត់មាន ។
មឿន :	គេទឹមតែហៅអញ្ចឹង ។
បូលី :	អត់មាន! មានតែគោកព្រេច មានតែអំពិល, រំដួល ។
មឿន :	អំពិល, រំដួល ខ្ញុំនៅតាមហ្នឹង ។
បូលី :	អញ្ចឹងមីងនៅក្នុងខេត្តឧត្តរមានជ័យដដែលហ្នឹង នៅស្រុកបន្ទាយអំពិល?
មឿន :	ចាស!
បូលី :	នៅម្តុំហ្នឹងពីណាគេអ្នកគ្រប់គ្រង?
មឿន :	ហ៊ឺ! គ្នាច្រើនដែលហ្នឹង ផ្លាស់ពីមួយទៅមួយៗ ខ្ញុំនៅដឹកជញ្ជូន នៅជាមួយតាខេង ។
បូលី :	តាខេង?
មឿន :	ចាស!
បូលី :	តាខេង ហ្នឹងដំណែងគាត់ជាអី?
មឿន :	គាត់នៅខាងក្តាប់អ្នកដឹកជញ្ជូន ខាងសេដ្ឋកិច្ច ។
បូលី :	មេដឹកជញ្ជូន?
មឿន :	ចាស!
បូលី :	ដឹកជញ្ជូនអីគេមីង?
មឿន :	ដឹកជញ្ជូនគ្រាប់, ដឹកជញ្ជូនអង្ករ, ដឹកជញ្ជូន... ។
បូលី :	ជញ្ជូនពីណាទៅណា?
មឿន :	ជញ្ជូនពីលើភ្នំមក ។
បូលី :	ពីលើភ្នំដងរែក?
មឿន :	ចាស!
បូលី :	យកទៅណាវិញ?
មឿន :	យកមកឲ្យទាហាននៅព្រំដែនហ្នឹង ក្រោម ។
បូលី :	ទាហាននៅខាងក្រោម?
មឿន :	ចាស!
បូលី :	ដែលកំពុងតែវ៉ៃជាមួយ ជាមួយរដ្ឋាភិបាលហ្នឹង?
មឿន :	ចាស!

បូលី ៖ មីងស្គាល់ សូ ហុង?

មឿន ៖ អត់ស្គាល់ទេ ។

បូលី ៖ តា សូ ហុង គាត់នៅខាងម៉ាល័យ, នី កនអី?

មឿន ៖ អត់ស្គាល់ទេ ។

បូលី ៖ ចុះមីងនៅក្នុងកងពលលេខប៉ុន្មាន?

មឿន ៖ នៅកងពល មិនដឹងនៅកងពលណាទេ កងពលតែពួកតា រ៉េត តាអីហ្នឹងឯង ។

បូលី ៖ ទុយ ប៉ុនរ៉េត?

មឿន ៖ ចា៎ស! តារ៉េត នៅ១០៥ រាល់ថ្ងៃនេះ ។

បូលី ៖ ១០៥ រាល់ថ្ងៃ ត្រកូលអីគេ?

មឿន ៖ អត់ស្គាល់ត្រកូលគាត់ទេ ។

បូលី ៖ ៥១៩?

មឿន ៖ មួយសារនោះគេហៅពួកកង៥២ ។

បូលី ៖ ពួក៥២ ប្រហែលជាពួកវរៈតាមមើល! អាចវរៈ ។

មឿន ៖ ចា៎ស! វរៈ៥២ ។

បូលី ៖ ប៉ុនកងពលវាមាន ៣លេខ ៥១៩, ៤១៧ អញ្ចឹង ។

មឿន ៖ នៅជាមួយតា អៀម, នៅជាមួយ តាខេង, នៅជាមួយតាអឿង តាអីហ្នឹងឯង ។ ស្គាល់តាអឿង ដែរនៅអណ្តូងវែង?

បូលី ៖ អត់ ។

មឿន ៖ ដល់ជួបគ្នា បានស្គាល់ ។

បូលី ៖ ឌុល សារឿង អីដែលឮ?

មឿន ៖ អត់!

បូលី ៖ សុខ ភាព?

មឿន ៖ អត់ទេ!

បូលី ៖ កងពល៤៥០?

មឿន ៖ ហ្នឹងដែលឃើញ ដែលដឹង៤៥០ ។

បូលី ៖ បាទ! ហ្នឹងកងពល៤៥០ហ្នឹងនៅខាងនេះឯង នៅខាងម៉ាល័យ នៅខាងអំពិល នៅខាងអីហ្នឹង! ខាងបន្ទាយមានជ័យ ។

មឿន ៖ គេហៅកង៥៥ កងអីសុទ្ធតែកងលោតឆ័ត្រ លោតហើរដល់ហើយ ។

បូលី ៖ បាទ! ហើយមីងនៅហ្នឹងនៅក្នុងកងដឹកជញ្ជូន?

មឿន ៖ ចា៎ស! កងដឹកជញ្ជូន។

បូលី ៖ កងដឹកជញ្ជូននារី ឬក៏បុរស?

មឿន ៖ ដឹកជញ្ជូននារីៗ គេហៅដឹកជញ្ជូន។

បូលី ៖ នៅក្នុងកងហ្នឹងមានស្រី មានប្រុសទេ?

មឿន ៖ ចា៎ស! ប្រុសៗគេអ្នកវ៉ៃ ស្រីៗអ្នកដឹកជញ្ជូន គេអ្នកការពារយើងទៀត។ គេការពារយើងជាអ្នកដឹកជញ្ជូន។

បូលី ៖ បាទ! អញ្ចឹងស្រីៗដឹកជញ្ជូន?

មឿន ៖ ចា៎ស!

បូលី ៖ នៅក្នុងកងហ្នឹងស្រីទាំងអស់តែម្តង?

មឿន ៖ ចា៎ស! ប្រុសខ្លះ ស្រីខ្លះ។ ដូចថាកម្លាំងខ្សោយទៅវ៉ៃគេមិនបានគេឲ្យនៅដឹកជញ្ជូនក្រោយទៅ។

បូលី ៖ បាទ! ហើយដឹកជញ្ជូនហ្នឹងមានប៉ុន្មាននាក់នៅក្នុងមួយកងហ្នឹង?

មឿន ៖ ទៅច្រើនណាស់កាលហ្នឹង។ មួយកង ពីរកងអី ២០នាក់ទៅ។

បូលី ៖ មួយកងសុទ្ធ២០នាក់អី?

មឿន ៖ ចា៎ស!

បូលី ៖ អូ៎! ច្រើនដែរអញ្ចឹង។ ហើយទៅមួយដងយើងដឹកបានប៉ុន្មានទៅបើយើងប្រើកម្លាំងដៃជើង?

មឿន ៖ បើគេឲ្យជញ្ជូនអង្ករ លីម្នាក់មួយបេៗទៅ បេសរយើងហ្នឹង ៥០គីឡូ។

បូលី ៖ មួយបេ ៥០គីឡូ?

មឿន ៖ ចា៎ស!

បូលី ៖ លីរួចដែរមីង?

មឿន ៖ រួច! បើគេបង្ខំហើយ ចេះតែទៅៗ។

បូលី ៖ ចុះគ្រាប់លីបានប៉ុន្មានគ្រាប់ទៅ?

មឿន ៖ បើលី អាកា! មានតែអាកា ទេធ្ងន់ជាងគេនោះ ម៉ាភពគ្រាប់មានតែអាកាទេធ្ងន់ជាងគេ។ មួយឡាំងៗ។

បូលី ៖ ម្នាក់មួយឡាំង?

មឿន ៖ ចា៎ស!

បូលី ៖ ស្ពាយនៅនឹងខ្លួនហ្នឹងតែម្ដង?

មឿន ៖ លី! ទូលលីៗ ។

បូលី ៖ ហើយពីលើភ្នំរហូតមកដល់ខាងក្នុងហ្នឹងចម្ងាយប្រហែលប៉ុន្មានគីឡូ?

មឿន ៖ ឆ្ងាយណាស់ ដេកផ្លូវក៏ឃើញដែរ ។

បូលី ៖ ដើរប៉ុន្មានថ្ងៃ?

មឿន ៖ ដួនណា២យប់ ២ថ្ងៃ ។

បូលី ៖ ២យប់ ២ថ្ងៃ មួយថ្ងៃយើងដើរបានប្រហែលជា៣-៤គីឡូដឺ ។

មឿន ៖ ចាស!

បូលី ៖ អញ្ចឹងយ៉ាងឆ្ងាយបំផុតក៏១០ គីឡូដែរ ។

មឿន ៖ ពួកខ្ញុំដឹកជញ្ជូនពីលើមក យកមកដាក់ជើងៗភ្នំ ។

បូលី ៖ អូ! យើងមិនមែនដឹកដល់ទីតាំងគេវៃទេនេះ?

មឿន ៖ កន្លែងគេវៃហ្នឹងឯង ។

បូលី ៖ កន្លែងគេវៃដែរ?

មឿន ៖ ចាស!

បូលី ៖ ឬក៏មីងគ្រាន់តែដឹកដាក់ជើងភ្នំហើយ គេកងទ័ពគេបញ្ជូនបន្តទៅកន្លែងវៃ?

មឿន ៖ បន្តទៅកន្លែងសមរភូមិទី១ ទី២ ស្នាក់ការទី៣ ។

បូលី ៖ ស្នាក់ការមានប៉ុន្មានទាំងអស់ ។

មឿន ៖ ស្នាក់ការទី១ ស្នាក់ការគេយកអ្នករបួសដូចថាគេវៃគ្នាហ្នឹង យកអ្នករបួសមកស្នាក់ការទី១ ខ្ញុំនៅស្នាក់ការទី២ ។

បូលី ៖ អីគេអាហ្នឹងទី២?

មឿន ៖ ទី២ សម្រាប់សែងគេដាក់ពេទ្យ ។

បូលី ៖ ចុះទី៣?

មឿន ៖ ទី៣ សែងខ្មោចៗ និយាយទៅគេយកទៅដាក់ត្រឹមស្នាក់ការទី៣ ។ ទី៣ យកទៅទៀតទៅ ។

បូលី ៖ អាណាជិតសមរភូមិជាងគេ?

មឿន ៖ ទី១ ។

បូលី ៖ អាទី១ ជិតសមរភូមិជាងគេ?

មឿន ៖ ចាស!

បូលី :　អាទី១ គឺថាសែងអ្នករបួស?

មឿន :　សែងអ្នករបួស ។ សែងមក សែងដាក់ស្នាក់ការទី២ ស្នាក់ការទី២ សែងដាក់មន្ទីរពេទ្យតែម្ដង ។

បូលី :　អាហ្នឹងទីពាមិនដឹងតាមមើល! អីអត់ទេ មន្ទីរពេទ្យមិនមែនស្នាក់ទេ?

មឿន :　អត់ស្នាក់ទេ! មន្ទីរពេទ្យធំ ។

បូលី :　អ៊ូ! អញ្ចឹងគេមានគន្លះគេ?

មឿន :　ចា៎ស!

បូលី :　បាទ! អាស្នាក់ការទី១ហ្នឹងគឺមានន័យថា វាកៀកនឹងសមរភូមិហើយ ។

មឿន :　កៀកសមរភូមិហើយ អាហ្នឹងពេទ្យប្រុសគេ ។

បូលី :　បាទ!

មឿន :　ចា៎ស! ដូចថា គេវ៉ៃគ្នារបួសអញ្ចឹងទៅ មានពេទ្យគេការពារទាហ៊ានទៅហ្នឹងៗ ហើយបាន គេសែងមកដល់នារីពួកខ្ញុំៗហើយ បានខ្ញុំសែងបញ្ជូនទៅមន្ទីរពេទ្យ ។

បូលី :　បាទ! អញ្ចឹងមីងសែងពីស្នាក់ការទី២ មកទីពា?

មឿន :　ចា៎ស!

បូលី :　គិតទៅគេមានបែងចែកច្បាស់លាស់របស់គេអញ្ចឹង?

មឿន :　ចា៎ស!

បូលី :　គេមិនឲ្យយើងទៅដល់សមរភូមិ កន្លែងដែលត្រូវគ្រោះថ្នាក់ទេអញ្ចឹងនោះ ។

មឿន :　ចា៎ស!

បូលី :　គេឲ្យមកត្រឹមយ៉ាងជិតបំផុតត្រឹមស្នាក់ការទី១?

មឿន :　ចា៎ស!

បូលី :　អញ្ចឹងតួនាទីរបស់មីងគឺថា ជញ្ជូនគ្រាប់ ជញ្ជូនស្បៀងផង ហើយនឹងជញ្ជូនអ្នករបួសផង?

មឿន :　ចា៎ស!

បូលី :　អ្នករបួសច្រើនទេមីង?

មឿន :　វ៉ៃគ្នាម្ដងៗច្រើនដែរហ្នឹង ។

បូលី :　វ៉ៃមួយដងរបួសប៉ុន្មាននាក់ដែរ?

មឿន :　បួន ដប់នាក់ ។

បូលី :　បួន ដប់នាក់ ហើយស្លាប់ច្រើនទេ?

មឿន :　ស្លាប់អត់សូវច្រើនទេ ស្លាប់មួយ ពីរ, ពីរ បី នាក់អីហ្នឹង ។

បូលី ៖ បាទ! ហើយក្នុងសម័យហ្នឹងផ្លូវប៉ុណ្ណា?

មឿន ៖ ផ្លូវតូច ៗ

បូលី ៖ ម៉ាប្រលោះដើរអញ្ចឹង?

មឿន ៖ ចា៎ស!

បូលី ៖ មានមីនទេតាមផ្លូវ?

មឿន ៖ មាន ៗ

បូលី ៖ ដែលមានអ្នកដើរទៅជាន់មីនទេ?

មឿន ៖ មាន ៗ

បូលី ៖ មីងឃើញនឹងភ្នែកទេ?

មឿន ៖ ចា៎ស! ផ្ទុះទៅបណ្តើរៗ ៗ

បូលី ៖ ចុះពេលដែលផ្ទុះទៅ យ៉ាងម៉េចទៅមនុស្ស?

មឿន ៖ ស្លាប់ ៗ

បូលី ៖ ស្លាប់តែម្តង?

មឿន ៖ ចា៎ស!

បូលី ៖ ហើយដែលមីងទទួលជញ្ជូនទៅលើភ្នំហ្នឹង គេមានឃ្លាំងគេទេ?

មឿន ៖ ឃ្លាំង ៗ

បូលី ៖ ឈ្មោះអីទេ ឃ្លាំងហ្នឹង?

មឿន ៖ កាលខ្ញុំទៅដឹកជញ្ជូននោះ ឃ្លាំងអត់មានដាក់ឈ្មោះទេ ៗ ខ្ញុំទៅកន្លែងអណ្តែងមុត ៗ

បូលី ៖ អណ្តែងមុត?

មឿន ៖ ចា៎ស! មានឃ្លាំងធំរបស់គេ ៗ

បូលី ៖ បាទ!

មឿន ៖ ចា៎ស! ចុះពីដីថៃមកដាក់ឃ្លាំងនៅហ្នឹង ៗ

បូលី ៖ អញ្ចឹងឃ្លាំងធំនៅដីថៃ?

មឿន ៖ ដីខ្មែរយើងដែរហ្នឹង ៗ

បូលី ៖ ដីខ្មែរយើងដែរ?

មឿន ៖ ចា៎ស! ខ្ញុំដឹងតែឃ្លាំងយើងហ្នឹងនៅដីខ្មែរយើងដែរ ៗ ពីព្រោះវៀតណាមវាត់ចូលតែដីខ្មែរតែមួយ ឈុលគេឲ្យយើងមកវិញហើយ មកនៅដីយើងវិញដដែរ ៗ

បូលី ៖ អាហ្នឹងដែលមីងនិយាយហ្នឹងគឺនៅក្នុងឆ្នាំប៉ុន្មាន?

មឿន ៖ កាលហ្នឹងខ្ញុំមិនទាន់បានអីគេផង ដឹកជញ្ជូនខ្ញុំនៅអណ្ដែងមុគៗ ដល់ពេលខ្ញុំមកបានគាត់នេះ ខ្ញុំនៅ១០០២ នៅដឹកជញ្ជូនមានគ្រួសារហើយនៅដឹកជញ្ជូនតិចៗហ្នឹង ។

បូលី ៖ មីងការឆ្នាំប៉ុន្មាន?

មឿន ៖ ៨០ ។

បូលី ៖ ១៩៨០?

មឿន ៖ ចាស៎!

បូលី ៖ ៨០គត់?

មឿន ៖ ចា៎ស!

បូលី ៖ ខែប៉ុន្មាន?

មឿន ៖ ខែ៣ មិនដឹងប៉ុន្មានទេ មិនសូវដឹងផង ។ កាលនោះការហើយជិតចូលឆ្នាំបណ្ដោយ ។

បូលី ៖ អ្ហូ! ការហើយចូលឆ្នាំខ្មែរតែម្ដង?

មឿន ៖ ចា៎ស!

បូលី ៖ អញ្ចឹងមីងដឹកជញ្ជូនហ្នឹង ដឹកមួយភ្លែតដែរហ្នឹងអញ្ចឹងនោះ ព្រោះបែក ៧ មករា ៧៩ រហូតដល់ មករា ៨០ វាមួយឆ្នាំ ហើយមកដល់ខែ៣ វាមួយឆ្នាំ ២ខែ ហើយមីងរត់អស់ប៉ុន្មានខែហ្នឹង អញ្ចឹងមីងធ្វើការដឹកជញ្ជូនគ្រាប់ ជញ្ជូនស្បៀងហ្នឹង ប្រហែលជិតមួយឆ្នាំតាមមើល៎!

មឿន ៖ ហ្នឹងឯង វាពិបាកពេក ។

បូលី ៖ ប្រហែលដែរ?

មឿន ៖ ចា៎ស! ពិបាកពេក គេថាទៅផ្ទះៗ ខ្ញុំក៏មកតាមគេទៅ កុំអីខ្ញុំនៅហ្នឹងរហូតហ្នឹង ។

បូលី ៖ ហើយម៉េចបាន បានការ ពូទៅរកមីង ឬក៏មីងទៅរកពូកាលហ្នឹង?

មឿន ៖ (សើច)ខ្ញុំដើរមក ដើរតាមមីងៗគេមានប្ដីមានអីហ្នឹងថា ទៅទន្លេល្ពៅៗ ទៅមុខម្ដុំស្រុកខ្ញុំហ្នឹងឯង គេចុះទៅដល់ថាចេះ ។

បូលី ៖ គេថាអញ្ចឹង?

មឿន ៖ ចា៎ស! ក៏ខ្ញុំប្រេចឈប់នៅហ្នឹងទៅ ក៏ខ្ញុំទៅទៀតទៅ ។

បូលី ៖ រត់មកជាមួយគេជាមួយឯងមក?

មឿន ៖ ចា៎ស!

បូលី ៖ មកទន្លេល្ពៅ?

មឿន ៖ ចា៎ស! មិនទាន់ដល់ទន្លេល្ពៅណា មកត្រឹម១០០២នេះ ។

បូលី ៖ បានត្រឹម១០០២?

មឿន ៖ ចាស! បានឪគេត្រឹម១០០២ ហ្នឹងឯង មានគេឆ្លងទន្លេតាមផ្លូវៗកើតកូនហើយ បានទៅមុខទៀតទៅបានខ្ញុំនៅៗ ក៏នៅទៅបាននៅគេទៅ ។

បូលី ៖ ១០០២ហ្នឹងនៅម្តុំណាមីង?

មឿន ៖ នៅចម្ការស្វាយ ។

បូលី ៖ នៅចម្ការស្វាយ?

មឿន ៖ ចាស!

បូលី ៖ នៅក្នុងខេត្តអី?

មឿន ៖ ខេត្តព្រះវិហារមិនដឹង ម្តុំហ្នឹង ។

បូលី ៖ ១០០២ ខេត្តព្រះវិហារ ។

មឿន ៖ ហួសផ្លូវព្រះវិហារទៀត ។

បូលី ៖ ហួសប្រាសាទទៀត?

មឿន ៖ ចាស!

បូលី ៖ ១០០២ អានេះ ១០០១ វាម្តុំពាទន្លេល្ពៅ?

មឿន ៖ ឆ្លងផ្តល់ជាតិ ផ្តល់កៅស៊ូខាងព្រះវិហារ ។ ដើរកាត់ដីថៃហ្នឹង ។

បូលី ៖ ដើរកាត់ដីថៃ អាដីកៅស៊ូដែលយើងមើលពីលើទៅឃើញហ្នឹង?

មឿន ៖ ចាស! ដើរឆ្លងហ្នឹងឯង គេថានោះប្រាសាទវិហារខ្មែរយើង ។ ព្រោះខ្ញុំដើរនៅលើដីថៃ ។

បូលី ៖ អូ! ឆ្នាំប៉ុន្មាន? ឆ្នាំ១៩៨០ហ្នឹង?

មឿន ៖ ចាស!

បូលី ៖ ពេលហ្នឹងមីងការប្តនៅ ពេលមីងដើរឆ្លងហ្នឹង?

មឿន ៖ មិនទាន់ការទេ!

បូលី ៖ អូ! អញ្ចឹងផ្លូវកៅស៊ូហ្នឹងមានយូរហើយអញ្ចឹង?

មឿន ៖ មានយូរហើយ ។

បូលី ៖ មិនមែនថៃ ទើបតែធ្វើមកទេអញ្ចឹង?

មឿន ៖ អត់ទេ! មានយូរហើយ ខ្ញុំឆ្លង ។

បូលី ៖ នេះអាហ្នឹងប្រវត្តិមួយសំខាន់ណាស់មីង ។ អ្នកភាគច្រើនគេថាថៃទើបតែធ្វើមកគាស់ផ្លូវកៅស៊ូហ្នឹង ។

មឿន ៖ ថៃទើបតមកទេដឹង បើថាខ្ញុំដើរឆ្លងកាត់ថ្នល់កៅស៊ូហ្នឹង ។

បូលី ៖ ពេលដែលមីងឆ្លងកាត់ឆ្នាំ៨០ ហ្នឹងមានថ្នល់កៅស៊ូហើយ?

មឿន ៖ ចា៎ស!

បូលី ៖ បានន័យថាថៃគេធ្វើយូហើយអញ្ចឹង ផ្លូវកៅស៊ូហ្នឹង?

មឿន ៖ ចា៎ស!

បូលី ៖ អញ្ចឹងមីងឆ្លងកន្លែងផ្លូវកៅស៊ូប្រាសាទព្រះវិហារហ្នឹង?

មឿន ៖ ចា៎ស!

បូលី ៖ ចាំមើល៎មីងឆ្លងៗម៉ុំណា កន្លែងនេះមានប្រាសាទមីង អានេះផ្លូវកៅស៊ូរបស់ថៃ ។

មឿន ៖ ឆ្លងដីថៃ ដឹងតែថ្នល់កៅស៊ូ ។

បូលី ៖ ផ្លូវនេះៗ អញ្ចឹងមីងដើរទៅអញ្ចឹងមក នេះ១០០៣បី មកឆ្លងផ្លូវប្រាសាទវិហារហ្នឹងផ្លូវ ១០០២ៗអាចម៉ុំនេះ ។

មឿន ៖ ចា៎ស! ១០០២ ចម្ការស្វាយ ចម្ការដំឡូង ។ កាលហ្នឹងគេហៅ ចម្ការស្វាយផង ចម្ការដំឡូងផង ។

បូលី ៖ ចម្ការស្វាយផង ចម្ការដំឡូងផង?

មឿន ៖ ច្រក១០០២ ហើយហ្នឹង ។

បូលី ៖ ច្រក១០០២ អាកន្លែងច្រកអានសេះហ្នឹងមែន?

មឿន ៖ ចា៎ស! ហ្នឹងហើយ ។

បូលី ៖ ហើយមកនៅហ្នឹង នៅជាមួយអ្នកណា ជាមួយកងទ័ព?

មឿន ៖ នៅជាមួយទ័ព ។

បូលី ៖ ពូនៅហ្នឹងដែរ?

មឿន ៖ នៅហ្នឹងដែរ ។

បូលី ៖ កាលបានពូ បាននៅ១០០២ហ្នឹង?

មឿន ៖ ចា៎ស!

បូលី ៖ មីងម៉េចក៏មិនឆ្ងាយដល់១០០១ ទន្លេល្ពៅទៅ?

មឿន ៖ គោលការណ៍ថាទៅដល់ហើយ ដល់ពេលគេឆ្លងទន្លេតាមផ្លូវទៅអត់រួច ។

បូលី ៖ នៅមើលគេសិន?

មឿន ៖ នៅមើលគេសិន គេថា២-៣ថ្ងៃរឹងដៃរឹងជើងឲ្យទៅទៀត ។ អញ្ចឹងខ្ញុំថាទៅទៀតហ្នឹងឯង ព្រឹកឡើងគេទៅបាត់ទៅ នៅពួកខ្ញុំប៉ុន្មាននាក់ ៣នាក់ហ្នឹង ។

បូលី ៖ អ៊ូ! ដល់ទៅហើយម៉េចវិញមីង ធ្វើយ៉ាងម៉េចបានជួបពូ វាម៉េច ឃើញគ្នាម៉េចអីម៉េច?

មឿន ៖ (សើច) កងគាត់នៅហ្នឹង គាត់នាំពួកខ្ញុំដេកសែងកូនគាត់នៅក្នុងអង្រឹងដេកសែងតាមផ្លូវ ប្រពន្ធគាត់ឆ្លងទន្លេ ក៏សែងសួរគាត់ គាត់ដើរទៅធ្វើការ ក៏សួរគាត់ថាជិតដល់ភូមិវាលឬនៅ គាត់ថាជិតដល់ហើយ! ជិតដល់ហើយ ខ្ញុំព្រឹកឡើងក៏សែងដាក់ភូមិវាលមក ធ្លាក់សុកធ្លាក់អី នៅរស់រហូតដល់ឥឡូវនេះ ។

បូលី ៖ អ្នកដែលឆ្លងទន្លេហ្នឹង?

មឿន ៖ ចា៎ស!

បូលី ៖ នៅណាឥឡូវហ្នឹង?

មឿន ៖ នៅផ្ទះនោះ ។

បូលី ៖ អ៊ូ! ផ្ទះក្បឿងហ្នឹង?

មឿន ៖ ចា៎ស!

បូលី ៖ ហើយម៉េចទៅបានជួបពូ?

មឿន ៖ ដល់អញ្ចឹងទៅ គាត់ឃើញខ្ញុំហើយគាត់សួរ ។

បូលី ៖ ពូ?

មឿន ៖ ចា៎ស!

បូលី ៖ គាត់សួរថាម៉េច?

មឿន ៖ គាត់សួរថា ព្រមយកគាត់អីៗអញ្ចឹង អត់ទៅមុខទៀតអីចឹង ។ បើគេអត់ទៅទៀតផង ខ្ញុំមិនដឹងទៅតាមពីណា ខ្ញុំនៅហ្នឹងទៅ នៅតាមគេ ។

បូលី ៖ ហើយមីងក៏ថាម៉េចទៅ?

មឿន ៖ ខ្ញុំអត់ថាម៉េចទេ! គាត់ដឹងថាស្រីៗតែសួរមិនឆ្លើយហើយ ដឹងថាយល់ព្រមហើយ ។

បូលី ៖ ខ្ញុំសុំឲ្យច្បាស់តិចមើស៎! គាត់សួរថាម៉េច?

មឿន ៖ គាត់ថា ព្រមយកគាត់ទេអី?

បូលី ៖ ហៅមិត្ត ឬក៏ហៅអូនកាលហ្នឹង?

មឿន ៖ ហៅមិត្ត ។

បូលី ៖ មិនមែនអូនទេ?

មឿន ៖ អត់ទេ!

បូលី ៖ សួរថាមិត្តព្រមយកខ្ញុំដែរអត់?

មឿន ៖ ចា៎ស!

បូលី ៖ បាទ! ហើយមីងអត់ឆ្លើយទេ?

មឿន ៖ អត់ឆ្លើយទេ ។

បូលី ៖ គ្រាន់តែញញឹម?

មឿន ៖ ចាស! សើច ។

បូលី ៖ ហើយក្នុងចិត្តមីងយ៉ាងម៉េចពេលគាត់សួរហ្នឹង?

មឿន ៖ ក្នុងចិត្តខ្ញុំគ្រាន់តែឆ្លើយថាយកប៉ុណ្ណឹង ។ ប៉ុនចិត្តទៅទៀតណាស់! សើច

បូលី ៖ ពេលដែលសួរហ្នឹងមីងមើលទឹកមុខគាត់ មីងពេញចិត្តគាត់ទេ?

មឿន ៖ ពេញក៏បាន មិនពេញក៏បានដែរ ។

បូលី ៖ ហេតុអីបានជាពេញ ឬក៏មិនពេញ?

មឿន ៖ ខ្ញុំខ្លាចគេ អត់ទាន់ស្គាល់គេ ខ្លាចគេអញ្ចឹងឆ្លើយថាយកគេទៅ យកហើយគេទៅទៀតទៅ ។

បូលី ៖ ម៉េចបានមីងសម្រេចចិត្តថាយក មូលហេតុអី?

មឿន ៖ គាត់ថានៅស្រុកនៅស្រែជាមួយគ្នាទេ ហើយខ្ញុំថាយកទៅ ។ ពួកខ្ញុំ៥នាក់ថាអត់យកទេ គ្រួសារទាំងអស់គ្នា បើគេយកហើយនៅតែខ្ញុំ ខ្ញុំមកជួបគាត់ទៅ គាត់ថានៅស្រុកជាមួយគ្នា ព្រមយកគាត់ទៅ ។

បូលី ៖ អូ! ដោយនៅស្រុកជាមួយគ្នា?

មឿន ៖ ចាស!

បូលី ៖ ឬក៏យកទៅ ដោយនៅម្នាក់ឯងវាតែលតោល?

មឿន ៖ ចាស!

បូលី ៖ នេះសំដីខ្ញុំទេ! មីងគិតម៉េច?

មឿន ៖ ហ្នឹងហើយនៅម្នាក់ឯងគេធ្វើបាប ។ យើងឆ្លើយថាយក មានគូរដណ្តឹងហើយគេមិនសួរនេះយើងទេ ធ្វើបាបអី គ្រាន់តែថាគេសួរយើងម្នាក់ហើយម្នាក់ទៀត គេសួរយើងឲ្យយកគេណា! ហើយយើងឆ្លើយថាយកគេទៅ គេលែងសួរយើងហើយ យើងថាមានគូរដណ្តឹងហើយគេលែងសួរហើយ ។

បូលី ៖ ហើយពេលដែលព្រមព្រៀងគ្នាហើយ ការនៅណា?

មឿន ៖ ការនៅចម្ការស្វាយ ។

បូលី ៖ ការប៉ុន្មានគូរ?

មឿន ៖ តែឯង ។

បូលី ៖ តែមួយគូរទេ?

មឿន ៖ ចាស! ពីរគូរថ្ងៃហ្នឹង ជិតដល់ថ្ងៃហើយម្នាក់ហ្នឹងជាន់មីនស្លាប់ទៅ ។

បូលី ៖ អ៊ូ! ប្រុស ឬស្រី?

មឿន ៖ ប្រុស ពីរគូរជាមួយខ្ញុំ ធ្វើដំណើរជាមួយគ្នាទៀតនោះ ។

បូលី ៖ ម្នាក់ស្រីហ្នឹងធ្វើដំណើរជាមួយដែរ?

មឿន ៖ ចា៎ស!

បូលី ៖ ខាងប្រុសជាន់មីនស្លាប់ទៅ?

មឿន ៖ ចា៎ស! ត្រូវការពីរគូរហ្នឹង ដល់ពេលជិតដល់ថ្ងៃហើយ គាត់ដើរទៅខ្សែត្រៀមគាត់ជាន់មីនផាប់ទៅ ។ ហើយប្រកែកជាមួយគេអត់ឈ្នះថា អត់ការទេតែឯង១ គេថាការទៅបើម្នាក់គ្នាពលីហើយធ្វើម៉េច ខ្ញុំព្រមការទៅ ។

បូលី ៖ ពិធីគេធ្វើយ៉ាងម៉េចខ្លះ គេធ្វើដូចយើង?

មឿន ៖ គេហៅយើងមេៗ គោរពវិញ្ញាណខ័ន្ធតិចតួច ។

បូលី ៖ អញ្ជឹងអត់មានស្លៀកពាក់អី?

មឿន ៖ ទេ! អត់មានទេ ។

បូលី ៖ កងដៃ កងជើងទេ?

មឿន ៖ អត់មានទេ!

បូលី ៖ ហើយមានជប់លៀងទេ?

មឿន ៖ មានបាយម្ហូបគេឲ្យមេៗ និងកូនទាហានតិចតួចហ្នឹង ។

បូលី ៖ ប៉ុន្មានមុខម្ហូប?

មឿន ៖ (សើច) ឆាត្រីខហ្នឹង ។

បូលី ៖ ត្រីខកំប៉ុងហ្នឹង?

មឿន ៖ ចា៎ស!

អ្នកជិតខាង ៖ ចា៎ស! អ្នកការជំនាន់ប៉ុល ពត ការមាតែត្រីខហ្នឹងហើយ ។

បូលី ៖ មីងការឬនៅ?

អ្នកជិតខាង ៖ ការហើយ ។

បូលី ៖ បើសិនចំអញ្ជឹងការអត់?

អ្នកជិតខាង ៖ បើសិនជាចំអញ្ជឹងការ ។

បូលី ៖ ការត្រីខណា៎?

អ្នកជិតខាង ៖ បើសិនជាខ្ញុំចំសង្រ្គាមអញ្ចឹងក៏ការកើត ការនឹងអំបិលក៏ការដែរ ។

បូលី ៖ ហើយមានតែត្រីខមួយមុខទេ ឬក៏មានអីទៀត?

មឿន ៖ មានតែត្រីខ ហើយនឹងនំយើងបុកម្សៅយើងធម្មតានឹងលាយជាមួយសណ្តែកចៀនជាមួយខ្លាញ់តែប៉ុណ្ណឹងឯង ។

បូលី ៖ ហើយការហ្នឹងពេលតែមួយព្រឹក ឬក៏មួយថ្ងៃពេញ?

មឿន ៖ តែមួយព្រឹកហ្នឹង ។

បូលី ៖ មួយព្រឹកទេ?

មឿន ៖ ចា៎ស! ការចាប់អារម្មណ៍ពីរបីមាត់ហ្នឹងចប់ ។

បូលី ៖ គេឲ្យយើងចាប់អារម្មណ៍យ៉ាងម៉េចខ្លះ?

មឿន ៖ (សើច) ខ្ញុំមិននិយាយទេ ឪវាអ្នកនិយាយ ។

បូលី ៖ បាទ! មានចាំទេ គាត់និយាយថាម៉េច?

មឿន ៖ គាត់និយាយប្តេជ្ញាចិត្តថាចេះៗទៅ ។

បូលី ៖ ខ្ញុំចង់ដឹងថារបៀបប្តេជ្ញាហ្នឹងគេធ្វើម៉េចវិញ? យើងលើកដៃចេះទេ?

មឿន ៖ អត់ទេ!

បូលី ៖ ឬគ្រាន់តែឡើងទៅឈរទេ?

មឿន ៖ គាត់និយាយ ។

បូលី ៖ គាត់និយាយថាម៉េចវិញ?

មឿន ៖ មានអី! មេៗគេនិយាយរួចហើយ ។

បូលី ៖ ប្តេជ្ញាហ្នឹង ប្តេជ្ញាថាយើងរស់នៅជាមួយគ្នា ឬប្តេជ្ញាបក្ស?

មឿន ៖ ប្តេជ្ញាមុខបក្សហ្នឹងឯងថា យើងមិនយកស្អីចោលគ្នាណា៎ ស៊ូស្លាប់ ស៊ូរស់ជាមួយគ្នា យើងចាប់ដៃគ្នាមិនឲ្យយកមួយហើយ មួយទៀតទេ ។

បូលី ៖ មានប្តេជ្ញាថាស្មោះត្រង់ជាមួយបក្សទេ?

មឿន ៖ អត់ទេ! គេឲ្យចាប់អារម្មណ៍ ។

បូលី ៖ ហើយមីងគេឲ្យចាប់អារម្មណ៍ដែរ?

មឿន ៖ ចា៎ស! តែខ្ញុំអត់មាននិយាយអីទេ ។

បូលី ៖ មីងអត់និយាយ ។ ម៉េចបានអត់និយាយអញ្ចឹងមីង?

មឿន ៖ ចុះបើគាត់និយាយហើយ ខ្ញុំខ្ជិលនិយាយតាមក្រោយទៀត ។

បូលី ៖ កាលហ្នឹងកងពលលេខប៉ុន្មាននៅ១០០២ហ្នឹង?

មឿន ៖ កងពល តាហឿន ។

បូលី ៖ តាហឿន?

មឿន ៖ ចាស!

បូលី ៖ គាហឿន នៅស៊ឹងត្រែងរាល់ថ្ងៃនេះហ្នឹង?

មឿន ៖ អត់ទេ! គាហឿននៅត្រពាំងប្រាសាទ ។

បូលី ៖ បាទ! គាត់ទៅធ្វើនៅភូមិភាគស៊ឹងត្រែង ភូមិភាគ២ ។

មឿន ៖ ដឹងម៉េច ។

បូលី ៖ ហើយ៦១២ មីងចាំទេ?

មឿន ៖ ៦១២ មិនសូវដឹងកងពល ។

បូលី ៖ ហើយការហើយគេឲ្យពូទៅក្រោមភ្នាម ឬក៏ឲ្យពូស្នាក់នៅខាងលើហ្នឹងមួយរយៈសិន?

មឿន ៖ នៅមួយអាទិត្យហ្នឹង ។

បូលី ៖ មួយអាទិត្យហើយគេឲ្យទៅកន្លែងវិញ?

មឿន ៖ ចាស!

បូលី ៖ កន្លែងពូនៅណា?

មឿន ៖ នៅខ្សែត្រៀមមុខ ។

បូលី ៖ ខាងក្នុងដីខ្មែរ?

មឿន ៖ ចាស!

បូលី ៖ ចុះមីងនៅខាងលើ?

មឿន ៖ នៅលើភ្នំ ។

បូលី ៖ នៅលើភ្នំនេះមក?

មឿន ៖ ចាស! គាត់ក៏នៅលើភ្នំដូចគ្នាដែរ ។ នៅពើយ ។

បូលី ៖ នៅពើយ?

មឿន ៖ ចាស! នៅពើយភ្នំដងរែក ។

បូលី ៖ ម៉េចគេហៅពើយ មើលអូនជួយចង្អុលតិចមើល!

មឿន ៖ ខ្ពស់លើកំពូលបង្អស់ហ្នឹងហើយគេហៅពើយ ។

បូលី ៖ អូ! អាកំពូលខ្ពស់លើគេហ្នឹង?

មឿន ៖ ហ្នឹងហើយគេហៅពើយ ។ ឲ្យតែខ្ពស់ផុតហើយ ហ្នឹងហើយពើយ ឡើងភ្នំផុតហើយដីរាបហើយ ។

បូលី ៖ ដីរាបហើយ?

មឿន ៖ ចាស! ឡើងទៅខ្ពស់ចុះទៅដីរាបហើយ ។

បូលី ៖ មីង! មិញមីងថាចម្ការស្វាយ ចម្ការដំឡូង?

មឿន ៖ ទៅពីខេត្តព្រះវិហារទៅភូមិថ្នល់ដាន ចេញពីថ្នល់ដានទៅបានភូមិចេកៗ ហើយបានចម្ការស្វាយ ហើយចម្ការដំឡូង ផុតចម្ការទៅបានទន្លេល្ពៅបណ្តោយ ។ មួយកន្លែងគាត់ដើរនៅរហូតហ្នឹង ។

បូលី ៖ ចុះមីងដែលព្រុសូរ ដាំតែ ទេ?

មឿន ៖ ហ្នឹងហើយ នៅដាំតែ ហ្នឹង ។

បូលី ៖ នៅដាំតែ?

មឿន ៖ ចា៎ស! ប៉ុន្តមិនមែនដាំតែក្រោមទេ នៅដាំតែលើ ។

បូលី ៖ (បង្ហាញផែនទី)

អ្នកជិតខាង ៖ មានទាំងអស់ លោកគ្រូមានទាំងអស់ សួរទៅចេញមានទាំងអស់ ។

មឿន ៖ នេះប្រាសាទអីគេ?

បូលី ៖ អាហ្នឹងប្រាសាទព្រះវិហារមីង ។ នេះត្រពាំងប្រាសាទយើងណា៎មីង នេះត្រពាំងប្រលាយ ផុតពីហ្នឹងមកបានចូលខេត្តវិហារ ស្រុកជាំសាននេះប៉ុន្តែនៅលើភ្នំដងរែកនេះ នេះប្រាសាទ ព្រះវិហារនៅម្តុំនេះ បានផុតពីហ្នឹងមកបានដាំតែ ផុតដាំតែមកបានអានសេះៗមកបានមុំបី នៅនេះ នេះមុំបីនៅនេះវិញ!

មឿន ៖ ចា៎ស!

បូលី ៖ អានេះ ទាល់តែឆ្លងមកបាតខ្ទះនេះ បានឡើងមកដល់មុំបី បាទអានេះអានសេះ ហើយនេះ ដាំតែ ។ ចុះកន្លែងមីងទៅប្រហែលនៅម្តុំណា? មីងចង្អុលមើល៍?

មឿន ៖ សាមតែ ក៏ខ្ញុំនៅ អានសេះក៏ខ្ញុំនៅដែរ ។

បូលី ៖ អានសេះក៏មីងនៅដែរ?

មឿន ៖ ចា៎ស!

បូលី ៖ ដាំតែក៏មីងនៅដែរ?

មឿន ៖ ចា៎ស!

បូលី ៖ ដាំតែ ឬសាមតែ?

មឿន ៖ គេហៅដាំតែមិនដឹង ។

បូលី ៖ ដាំតែ អញ្ចឹងហើយ ដូចគេហៅដាំស្វា, ដាំស្រង៉ាន់ ។

មឿន ៖ ចា៎ស!

បូលី ៖ ចុះ១០០២ហ្នឹងនៅម្តុំណាវិញមើលទៅ?

មឿន ៖ ១០០២ ចាប់ពីចម្ការដំឡូងមកខាងដែលខ្ញុំថាសាមតែហ្នឹង ។

បូលី ៖ មានចម្ការដំឡូង មានចម្ការស្វាយ ។ ចម្ការស្វាយ មានដើមស្វាយច្រើនយ៉ាងម៉េច?
មឿន ៖ មានដើមស្វាយៗចាស់ ។
បូលី ៖ ដើមស្វាយចាស់?
មឿន ៖ ចា៎ស! មិនដឹងប្រជាជននៅតាំងពីកាលណាទេ ។ ខ្ញុំនិយាយលើភ្នំ ខ្ញុំអត់និយាយដីខ្មែរយើងដីរាបនេះទេ ។
បូលី ៖ បាទៗ! នៅលើភ្នំដងរែកយើងនេះ?
មឿន ៖ ចា៎ស! ចម្ការស្វាយ គេហៅដើមស្វាយៗនោះ ។
បូលី ៖ បាទ! អាហ្នឹងគេហៅច្រក១០០២ហ្នឹង?
មឿន ៖ ចា៎ស! ច្រក១០០២ ចាប់ពីខេត្តព្រះវិហារឆ្លងផ្លូវកៅស៊ូទៅ១០០២ ទៅដល់ចម្ការស្វាយ បានពីត្រឹមចម្ការស្វាយមកលិចបានគេហៅ១០០២ បើទៅកើតទៀតគេហៅទន្លេល្អៅហើយ គេហៅ១០០១ ។
បូលី ៖ ច្រក១០០២ហ្នឹង ដែលគេហៅថាច្រកហ្នឹង ដោយតែមានច្រកចុះមកក្រោមឬក៏ម៉េច?
មឿន ៖ ខ្ញុំអត់សូវដឹងច្រកគេចុះមកក្រោមម៉េចទេ ខ្ញុំជាប់នៅលើភ្នំ ។
បូលី ៖ មីងនៅហ្នឹងគឺកងរបស់តាហឿន?
មឿន ៖ ចា៎ស!
បូលី ៖ កងតាហឿនហ្នឹងគឺកង៦១២?
មឿន ៖ ចា៎ស! កង៦១២ ។
បូលី ៖ បាទ! ហើយនៅហ្នឹងក្រៅពីកងតាហឿន មានកងណាផ្សេងទៀតទេ?
មឿន ៖ ទេ! កងច្រើនណាស់កាលហ្នឹង ។
បូលី ៖ កងពលរបស់តាហឿន មានកងពលណាទៀតទេ?
មឿន ៖ តាសន ដូចកងពលដែលមិនដឹង តាសន ។
បូលី ៖ តាសន ត្រពាំងប្រាសាទយើងនេះ?
មឿន ៖ ចា៎ស!
បូលី ៖ លក់ស្រាបៀរ?
មឿន ៖ ចា៎ស! ខ្ញុំមកជួបគាត់ គាត់វរៈសេនាធំ កងធំ ។
បូលី ៖ វរៈសេនាធំវានៅក្រោមកងពលរបស់តាហឿន?
មឿន ៖ នៅជាមួយតាហឿនហ្នឹងឯង ។
បូលី ៖ មីងនៅហ្នឹងមានប្រហែលប៉ុន្មានគ្រួសារ?

មឿន ៖ អត់មានប្រជាជនទេ មានតែគ្រួសារទាហ៊ាន ។

បូលី ៖ ហ្នឹងហើយប៉ុន្មានគ្រួសារ?

មឿន ៖ ច្រើនដែរហ្នឹង ។

បូលី ៖ ហើយយើងធ្វើផ្ទះធ្វើសម្បែងអីនៅយ៉ាងម៉េចទៅ?

មឿន ៖ ធ្វើផ្ទះតូចៗហ្នឹង ផ្ទះប៉ុនៗនេះអស់ធំហើយ ។

បូលី ៖ ខ្ទមៗនេះ?

មឿន ៖ ចា៎ស!

បូលី ៖ ធ្វើពីអីវិញ?

មឿន ៖ ពីឈើៗ កាប់ដើមល្មៀង ដើមអីហ្នឹងធ្វើ តែប្រកដំបូលស្បូវ ។

បូលី ៖ ដំបូលប្រកស្បូវ ចុះជញ្ជាំង?

មឿន ៖ ជញ្ជាំងក៏ស្បូវ ។

បូលី ៖ អត់មានឫស្សីទេ?

មឿន ៖ អត់ទេ!

បូលី ៖ ចុះរនាប?

មឿន ៖ រនាបឫស្សី ពុសឫស្សី បើអត់ឫស្សី ជួនណាពុសដើមត្រែងយើងហ្នឹង ។

បូលី ៖ ហើយបានកូនទី១ ហ្នឹងឆ្នាំណា?

មឿន ៖ ឆ្នាំ៨១ ឬ៨០មិនដឹង ។ (សើច)

បូលី ៖ អេ! មីងការ៨០ ។

មឿន ៖ អត់មានទំនេរពោះផង ។

បូលី ៖ អត់មានទំនេរពោះសោះតែម្តង?

មឿន ៖ ចា៎ស! ចរ ៨០ ។

បូលី ៖ កូនមីងឆ្នាំ ចរ?

មឿន ៖ ចរ កូនច្បង ។

បូលី ៖ ឆ្នាំ ចរ អាច៨២ណាមីង!

មឿន ៖ ខ្ញុំថាដូច៨១ ។

បូលី ៖ បើ៨១ក៏ចុងដែរ មិនអាចដើមទេ ។

មឿន ៖ ចា៎ស!

បូលី ៖ មីងការខែប៉ុន្មាន?

មឿន ៖ ខ្ញុំថា បើមិនខែ៣ ខែ៤ ការចូលឆ្នាំបណ្ដោយ ។

បូលី ៖ ការហើយចូលឆ្នាំ ថាខែ៤ចុះណាំ ។ ខែ៤ យើងពរពោះមិន៩ខែ ១០ថ្ងៃ, វា ៤បូកនឹង៩ វា១៣ អញ្ចឹងខែ១ ៨១ អាចចន្លោះដើម៨១ កូនមីង ។

មឿន ៖ ចាំស! ៨១ មិនដឹង ខ្ញុំថា៨១ បើមិន៨១ក៏៨០ ដែរ ។

បូលី ៖ បាទ! កើត៨១ ។ ហើយនៅហ្នឹងបានអង្ករត្រី សាច់អីមកពីណាទៅ?

មឿន ៖ គេបើកឲ្យ ។

បូលី ៖ បើកពីណាមកវិញ?

មឿន ៖ មិនដឹងបើកពីណាពីណីទេ អង្ករញ៉ុកៗឃ្លាំងអញ្ចឹង ។

បូលី ៖ អ៊ូ! គេចែកម៉េច? ម្នាក់បានប៉ុន្មាន?

មឿន ៖ គេចែកឲ្យហូបម្នាក់ក្នុង១ខែ៦០គំប៉ុង ។

បូលី ៖ អ៊ូ! ច្រើនណាស់ណាំ?

មឿន ៖ ចាំស! ហើយខ្ញុំជាអ្នកវាល់ឲ្យគេ ។

បូលី ៖ អ៊ូ! មីងអ្នកចែករបបឲ្យគេ?

មឿន ៖ ចាំស! ចែករបបឲ្យគេ ។ ដូចថាគេដឹកមួយឡានមក គេឲ្យយើងគិតប្រជាជនមានប៉ុន្មាន ម៉ាគ្រួសារហូបប៉ុន្មាន? គេដឹងថាម្នាក់៦០គំប៉ុង ។

បូលី ៖ ម្នាក់៦០គំប៉ុង?

មឿន ៖ ៦០គំប៉ុងក្នុងមួយខែ ។ យើងគិតក្នុងបាវប៉ុន្មានរយគំប៉ុង គិតក្នុងហ្នឹង ។

បូលី ៖ ហើយប៉ុន្មានរយនាក់ទៅទាំងអស់?

មឿន ៖ ច្រើនរយដែរហ្នឹង ។

បូលី ៖ មីងមានចាំទេថាមីងចែកឲ្យគេអស់ប៉ុន្មានរយនាក់ម្ដង?

មឿន ៖ បើកាណាច្រើនក៏១០០នាក់ទៅចែក បើកាលណា៥០នាក់ទៅ រត់ទៅជុំគ្នាទៅក៏នេះ បើបែកគ្នាខ្លះគេរត់ទៅនេះ ខ្លះរត់ទៅនោះស្រេចតែគេទៅ គេនៅកន្លែងនេះមិនស្រួលគេរត់ទៅនោះទៀត កន្លែងផ្សេងៗគ្នា ។

បូលី ៖ ហើយពូចុះទៅធ្វើការហ្នឹង វិលមកសម្រាកផ្ទះវិញ ឬក៏យូរៗមកម្ដង?

មឿន ៖ យូរៗមកម្ដង ។

បូលី ៖ មិនមែនមករាល់យប់ទេ?

មឿន ៖ ទេ!

បូលី ៖ ប៉ុន្មាន ចន្លោះពេលប៉ុន្មានបានពូគាត់មកលេងម្ដង?

មឿន ៖ មួយខែ ពីរខែ ។

បូលី ៖ មួយខែ ពីរខែមកម្តង?

មឿន ៖ ចាស!

បូលី ៖ ហើយមីង១នៅខាងក្រោយនឹងទៅ?

មឿន ៖ ចាស!

បូលី ៖ ហើយមានជញ្ជូនគ្រាប់ ជញ្ជូនអីទៅទៀតទេ?

មឿន ៖ កាលខ្ញុំមានកូនខ្ញុំអត់ដែលជញ្ជូនទេ ។ ទើបតែបានគាត់ដឹកជញ្ជូន ប៉ុនដឹកជញ្ជូនស្រួលណាស់ ជញ្ជូនមិនបង្ខំចិត្តដូចកាលយើងនៅនារីទេ យើងយកតាមសម្រួលតាមដែលយើងយករួច បើខ្ញុំនៅដឹកជញ្ជូននារីកំណត់តែម្តង ធ្វើម៉េចឲ្យ ដូចថាដឹកជញ្ជូនឡានដឹកមក១០ឡាន អីអញ្ចឹងទៅ ជញ្ជូនមួយយប់ឲ្យហើយ ឲ្យហើយចែកកេះគ្នាទៅ ។

បូលី ៖ ហើយមីងដូចថា ពេលនៅ១០០២ហ្នឹង មានរត់មានអីទេ?

មឿន ៖ រត់១ដូចតែគ្នា តែខែប្រាំងរត់ហើយ ។

បូលី ៖ ខែប្រាំងរត់?

មឿន ៖ ចាស! ខែប្រាំងរត់ហើយ ។

បូលី ៖ មីងនៅ១០០២ហ្នឹងដល់ឆ្នាំណា?

មឿន ៖ ខ្ញុំនៅ១០០២ បានកូនមួយហ្នឹង មកកើតនៅអូររំចេក ។

បូលី ៖ អូររំចេក?

មឿន ៖ អ្ហូ! កើតនៅអូររំចេកអី នៅភ្នំគ្រប់ ។

បូលី ៖ នៅភ្នំគ្រប់យើងនៅព្រះវិហារនេះហ្នឹង?

មឿន ៖ ចាស! កើតនៅហ្នឹង រត់ចុះរត់ឡើង ។

បូលី ៖ ម៉េចបានមកកើតនៅហ្នឹងវិញ?

មឿន ៖ ចុះវៃគ្នា រត់វៃគ្នានោះ គ្មានបាននៅជាប់ណា ផ្លាស់ចុះផ្លាស់ឡើងគ្មានដែលបាននៅផ្ទះតែ មួយកន្លែងទេ ។

បូលី ៖ វៃជាមួយយួនហ្នឹង?

មឿន ៖ ចាស! មើលតែនេះហ្នឹងវៃគ្នារត់ហើយ សភាពការណ៍មិនស្រួលរត់ទៅទៀតហើយ ធ្វើតែ ផ្ទះចោល ។

បូលី ៖ បាទ! ដុតផ្ទះចោល?

មឿន ៖ ផ្ទះតែនេះគេចូលទៅដុតចោលទៅ អ្នកណាទៅនៅចោលអញ្ចឹងទៅ ។

បូលី ៈ ឡូតែពេលណាគេវ៉ៃយើងរត់ទៅ?

មឿន ៈ ចា៎ស!

បូលី ៈ ខែវស្សានៅទៀតទៅ?

មឿន ៈ ចា៎ស!

បូលី ៈ ឆ្នាំ៨៤-៨៥ ពេលហ្នឹងវៀតណាមវ៉ៃខ្លាំងទេមីង?

មឿន ៈ វ៉ៃគ្នាកាលហ្នឹងវ៉ៃគ្នា ឪវាមិនសូវបាននៅទេ ។

បូលី ៈ អញ្ចឹងពេលមីងចេញពី១០០២មីងទៅនៅណាវិញ?

មឿន ៈ ចេញពី១០០២មកលិចវិញ ។

បូលី ៈ បកក្រោយវិញ?

មឿន ៈ ចា៎ស!

បូលី ៈ មកនៅណាវិញ?

មឿន ៈ ចេញពី១០០២ខ្ញុំបានគាត់ហើយ បានទៅនៅនោះ ដូចខ្ញុំថាហ្នឹងឯង ។ បានខ្ញុំចាក់មកនៅត្រឹម៤០ ។

បូលី ៈ អ៊ូ! មកនៅត្រឹម៤០វិញ?

មឿន ៈ ចា៎ស! ហ្នឹងហើយខ្ញុំបានកូនមួយ កូនពីរហើយហ្នឹង ។

បូលី ៈ មីងបានកូនប៉ុន្មានហើយមកនៅ៤០ហ្នឹង?

មឿន ៈ ខ្ញុំកើតកូនអាទី២ ។

បូលី ៈ អាទី២?

មឿន ៈ ចា៎ស!

បូលី ៈ អាទី២ហ្នឹងកើតឆ្នាំប៉ុន្មាន?

មឿន ៈ ឆ្នាំជូត មិនសូវចេះគិតឆ្នាំ ។

បូលី ៈ ឆ្នាំជូត កណ្តុរ ។ ចរ កោរ ជូត អញ្ចឹងមីងចន្លោះមួយឆ្នាំអញ្ចឹង មិនមែនបន្តកន្ទុយគ្នាណា៎?

មឿន ៈ អត់ទេ! បីឆ្នាំពីរ ។

បូលី ៈ បីឆ្នាំពីរ អញ្ចឹង៨៣ ។ អាបងគេ៨១?

មឿន ៈ ចា៎ស!

បូលី ៈ អាទី២ ៨៣?

មឿន ៈ ចា៎ស!

បូលី ៖ ៨៣ ហើយអញ្ចឹង ។ អញ្ចឹងមីងមកនៅ៨០ នេះខ្ទង់ឆ្នាំ៨៣ ឬក៏៨៤ ។

មឿន ៖ មើលនៅអា៨០ ក្រោមហ្នឹងខ្ញុំបានអាបង់ទេ មកអាទី២នេះកើតនៅក្បាលអូរខ្សាច់នេះ ចម្ការអំពៅ ស្គាល់ទេ?

បូលី ៖ ចម្ការអំពៅ ម្តុំណាវិញ?

មឿន ៖ ចម្ការអំពៅយើងនេះ ស៊ឹងច័ន្ទ ។

បូលី ៖ អូ! ស៊ឹងច័ន្ទ?

មឿន ៖ ចាស! ខ្ញុំកើតអាទី២ ។

បូលី ៖ ស៊ឹងច័ន្ទ នៅខាងក្រោយអូរគ្រាវ ។

មឿន ៖ ចាស! ហ្នឹងហើយខ្ញុំកើតអាទី២ ហ្នឹងឯងនៅស៊ឹងច័ន្ទហ្នឹង ។

បូលី ៖ អូ! នេះអូរគ្រាវ ។

មឿន ៖ ហ្នឹងកំពុងរត់ហើយនោះ រត់ចូលទៅដីថៃនៅចម្ការម្ទះនោះ រត់ហ្នឹងខ្ញុំទាស់ចង់ងាប់ចង់រស់ ខ្ញុំស្មានតែមិនរស់ផងខ្ញុំ ។

បូលី ៖ អាហ្នឹងពេលយួនវ៉ៃចូលខ្លាំងហ្នឹង?

មឿន ៖ ចាស! ខ្ញុំផ្តាច់ដោះកូនហ្នឹងឯងខ្ញុំទាស់ សន្ទប់ស្លក ធ្វើតួបៗនៅមួយគ្រាប្រកគង់នៅអញ្ចេះឯង ខ្ញុំសន្ទប់បាត់ហើយ ទាស់គ្នាចង់ងាប់ ។

បូលី ៖ ខ្ញុំគិតថា កូនមីងទី២ កើត៨៤ កូនទី១ ៨២?

មឿន ៖ អត់បានគិតមើលផង ដឹងតែឆ្នាំចរ ឆ្នាំជូត ។

បូលី ៖ ព្រោះដែលបើឆ្នាំចរ ៨២, ឆ្នាំជូត ៨៤ ។

មឿន ៖ ចាស! ខ្ញុំកើតនៅស៊ឹងច័ន្ទហើយ បានរត់មកនៅជាំស្វា វិញរត់រហូត ។

បូលី ៖ រត់ពីស៊ឹងច័ន្ទ?

មឿន ៖ ខ្ញុំថាត្រឡប់ត្រលិនហ្នឹង រត់រហូតហ្នឹងមិនដែលនៅជាមួយគ្នាទេ ។

អ្នកជិតខាង ៖ អញ្ចឹងបានគេរឿងជំនាន់ប៉ុល ពត មើល ស្តាប់រឿងមីម៉ារនីនោះដក់ត្រចៀកណាស់ ។

មឿន ៖ ម៉ាប្រាំងនេះ ជិតបោះឆ្នោតស្តាប់រឿងម៉ារនីរហូត ស្តាប់អត់ចេះខុសទេ ។

បូលី ៖ អញ្ចឹង! រឿងអីគេ?

មឿន ៖ រឿងម៉ារនី ។

បូលី ៖ គេថាផ្សាយតាមណាហ្នឹង?

មឿន ៖ តាមវិទ្យុ (radio) ។

បូលី ៖ តាមវិទ្យុអីគេ?

មឿន :	តាមរដ្យ៉ូប៉ុស្ដិ៍បាយ័ន ។ ថារឿងខ្ញុំ ហើយនឹងរឿងម៉ារនី មិនខុសពីរឿងខ្ញុំទេ ។

បូលី :	អ៊ូ! ឥឡូវៗនេះទេ?

មឿន :	ច៊ាស! រត់ចុះរត់ឡើងៗមិនដែលបាននៅស្រួលទេ ។

បូលី :	ឲ្យតែគេវ៉ៃយើងរត់ទៅ?

មឿន :	ច៊ាស!

បូលី :	ស៊ីងច័ន្ទនេះនៅជ្រៅក្នុងដីថៃទេ នៅជ្រៅជាងអូរត្រាវទៀត?

មឿន :	ស៊ីងច័ន្ទហ្នឹង?

បូលី :	បាទ!

មឿន :	ទេ! នៅម៉ាជួរគ្នាហ្នឹងឯង ប៉ុនគ្រាន់ថាអាមួយនៅខាងកើត អាមួយនៅខាងលិចតែប៉ុណ្ណោះឯង ។

បូលី :	អាមួយកើត អាមួយលិច?

មឿន :	ច៊ាស!

បូលី :	នៅម្ដុំអូរត្រាវហ្នឹងដែរ?

មឿន :	ពីព្រោះខ្ញុំឆ្លងពីអូរត្រាវនេះមកនៅស៊ីងច័ន្ទចម្ការអំពៅជិតជាំស្លានេះ ឆ្លងពីកូនអូរភូមិថៃនៅនេះដើរកាត់នេះឯង ផ្ទះថៃនៅ ។ ច៊ាស!ឆ្លងមកបាននៅជាំស្លាបណ្ដោយ ។

បូលី :	អ៊ូ! ចុះដងទង់ដែលនៅទេ?

មឿន :	ហ្នឹងហើយដងទង់ឯង ។

បូលី :	ដងទងជាំស្លាហ្នឹង?

មឿន :	ច៊ាស!

បូលី :	ក្បែរគ្នាហ្នឹង?

មឿន :	ក្បែរគ្នាហ្នឹងឯង ។

បូលី :	ក្បែរជប់រុនដែរអញ្ចឹង?

មឿន :	ជប់រុន នៅនេះទេ! ជប់រុន នៅយើងដីនេះ ដល់ពេលយើងមិនឡើងភ្នំទៅជប់រុនៗទៅចម្ការម្ទេស ចម្ការម្នាស់នៅខាងលិចហ្នឹងបន្តិច ចម្ការម្ទេសបានទៅជាំស្លាបណ្ដោយ ។

បូលី :	បាទ! បានន័យថា ជាំស្លាហ្នឹងនៅក្នុងដីថៃ?

មឿន :	ខ្ញុំថាដីយើងដែរ ។

បូលី :	ដីយើងដែរ?

មឿន :	ច៊ាស! បើដីថៃវាមិនឲ្យយើងនៅទេ ។ វាដាក់បង្គោលដាក់អីហើយ ។

បូលី ៖ កាលហ្នឹងថៃវាឲ្យជនភៀសខ្លួននៅច្រើនតាមព្រំដែន ។

មឿន ៖ ប៉ុនយើង គេប្ដូងទៅពីនេះដល់អាម៉ុំផ្ទះពួកខ្ញុំនៅ ពួកខ្ញុំរត់ទៅគេដាក់ឈើខ្វែងបេះ គេអត់ឲ្យយើងទៅមុខទៀតទេ ។

បូលី ៖ ពីណាដាក់?

មឿន ៖ ថៃ ។

បូលី ៖ អ្ហូ!

មឿន ៖ ចា៎ស! អត់ឲ្យចូលដីវាទេ ។ បើថាធ្លាក់ខ្លាំងហ្នឹងឲ្យចូលម៉ាឆុល ហើយបិទវិញ ។

បូលី ៖ គេមានដាក់អាឈើខ្វែងហ្នឹងដែរ?

មឿន ៖ ចា៎ស! ដាក់ឈើខ្វែង គេនៅយាមហ្នឹង ។ ពេលធ្លាក់ខ្លាំងគេដឹងថាធ្លាក់ឆឹងៗកន្លែងផ្ទះយើងហើយ យើងរត់ចូលមកឆុលទៅ ។

បូលី ៖ ហើយមានឆេះផ្ទះឆេះអីទេ ពេលបាញ់គ្នាហ្នឹង?

មឿន ៖ ខ្លះឆេះ ខ្លះអត់ទៅ ។

បូលី ៖ ហើយដល់ពេលយើងរត់ហ្នឹង យើងមានយកអីទៅតាមខ្លួនបានខ្លះ?

មឿន ៖ គ្មានបានអីទេ! ខោអាវថ្មីៗកប់បានសល់ បើខោអាវចាស់ៗយើងស្លៀកទៅយើងរត់ កុនខ្លាំងក្រវាត់ចោលទៅ ដេកពាក់កែងស្បែកជើងស្រេចយប់ឡើង ថ្នារនេះបាយឆ្អិនអស់ហើយ ។

បូលី ៖ អញ្ជឹង?

មឿន ៖ ចា៎ស! ថ្នារនេះបាយឆ្អិនពូតបាយដាក់ទុកឲ្យកូនស៊ី ។

បូលី ៖ យើងត្រៀមជានិច្ច?

មឿន ៖ ចា៎ស! ត្រៀម ហើយអង្ករដាក់ស្រេច ឆ្នាំងមួយ អង្ករពីរ បីកំប៉ុងទៅ ថ្នក់កូនហ្នឹងអង្រឹងមួយធ្វើយ៉ាងម៉េចឲ្យតែបានប៉ុណ្ណឹងរួចហើយ ដល់ពេលយើងមើលទៅថាកុនខ្លាំងព្រាត់ហ្នឹងចោលទៀតទៅ អត់បាយមួយយប់មួយថ្ងៃទៅ ។ កូនខ្ញុំអាទីមួយ ហ្នឹងហើយយំចង់ដាច់ខ្យល់ ។

បូលី ៖ យំរឿងអី?

មឿន ៖ យំវាឃ្លានបាយវា គេប្រមាថចោលហ្នឹងជ្រូកក៏ឃើញអីក៏ឃើញ ខ្ញុំវេទនារត់មិនដែលបានជុំអីទេ រត់តែឯងៗ គាត់មិនដែលនៅជុំជាមួយខ្ញុំផង ។

បូលី ៖ ពេលរត់ហ្នឹងយើងយកតែរបស់ហូបទេណ៎?

មឿន ៖ ចា៎ស! មានមី មាននំមានអីយើងដាក់ម៉ាឡូស្រេច ។

បូលី ៖ ចុះកូនដាក់ណាទៅ?

មឿន ៖ កូនដាក់នៅនឹងថ្នក់ក្រម៉ាយើងទៅ ដេកដាក់ចងថ្នក់ស្រេច ក្រម៉ាយើងហ្នឹងចងវាត់ឈៀង ដេកនៅហ្នឹងឯង ញុពុងញាំងៗដាក់ថ្នក់វត់ៗ

បូលី ៖ ដាក់ថ្នក់វត់តែម្តងៗ កូនដាក់ពីមុខទៅ?

មឿន ៖ ចាស!

បូលី ៖ អាតូច?

មឿន ៖ ចាស!

បូលី ៖ ចុះធំ?

មឿន ៖ អាធំវ៉ៃគ្នាខ្លាំងមានតែបងហ្នឹងឯង ដល់ពេលចេះស្រួលតិចៗទៅមិនសូវបាននេះ បើថាកូនច្រើនដូចរាល់ថ្ងៃមិនទៅរត់រួចទេៗ អាទីមួយឯងរត់ ចង់ផាប់ចង់រស់ ប្រមាថវាយកចោលនឹងជ្រោះក៏ឃើញអីក៏ឃើញវាយំ វាឃ្លានវានោះមួយយប់ទល់ភ្លឺ គេថាកម្លាំងគេរាប់រយឯងតែមួយ ខាតកម្លាំងគេ គេឲ្យបោះចោល ខ្ញុំបោះចោលទៅ ខ្ញុំក្រាញនៅបោសដីដេកជាមួយកូនហ្នឹងៗ

បូលី ៖ ពីណាគេជាអ្នកថាឲ្យបោះចោល?

មឿន ៖ មេៗគេហ្នឹង គេខ្លាចខូចកម្លាំងគេច្រើន ឯងយំអំពុលទុក្ខគេ គេប្រមាថឲ្យបោះចោលទៅខ្ញុំថាខ្ញុំខ្លាច មានពូៗខ្លះគេអាណិតយើង គេថាតោះបើគ្នាមិនខ្លាច គ្នាទុកឲ្យគេបាញ់ចោលនៅផ្ទះ គ្នាខ្លាចហ្នឹងបានគ្នារត់មក គាត់ចេះតែបណ្តើរខ្ញុំ គេបន្តឲ្យនំស៊ីទៅស្ងាត់ដូចខ្ញុំថានិយាយប្រាប់ពួកនេះគេមិនជឿខ្ញុំទេ ឲ្យម៉ីមួយកញ្ចប់ទៅស៊ីបាត់ទៅ លក់ម៉ឺលអញ្ចឹងទៅដើរដួលពពុសចុះយប់នោះ បុកក្បាលថ្មក៏ឃើញអាឈើក៏ឃើញដួល តែម៉ែដួលអាកូនក៏ដួលដែរនៅនឹងថ្នក់ក្រម៉ាហើយ ភ្ញាក់វាគេស្រែកទៀតៗគេប្រមាថទៀតហើយ!

បូលី ៖ ហើយមើលម៉េចឃើញបើយប់ងងឹតអញ្ចឹង?

មឿន ៖ មានពិលណាចុចៗ

បូលី ៖ ដើរយ៉ាងម៉េចទៅ ដើរវាវៗយ៉ាងម៉េច?

មឿន ៖ ដើរវ៉ាវៗឡើងភ្នំចុះអូរ អូរចុះភ្នំ ចង់ផាប់ចង់រស់សម័យហ្នឹង គ្នានមានពិលណាចុចដើរបានឃើញផ្លូវនោះៗ

បូលី ៖ គេចពីទាហានយួន?

មឿន :	ចា៎ស! កម្លាំងគេរាប់រយ គេខ្លាចខូចកម្លាំងគេ ឯងកូនយំមួយ គេបន្តនំឲ្យស៊ីមួយសន្ទុះបាត់ អញឹងទៅវាស្រងំលក់ ងើបដើរទៀត យើងដើរទៀតទៅមិនដួលទៀតហើយដួលទៅបុក ឈើហ្នឹងហើយ ។

បូលី :	ហើយចុះបើគ្រាន់តែក្មេងយំហ្នឹងកើតអី?

មឿន :	ខ្លាចបែកការណ៍ កម្លាំងគេ ។

បូលី :	ខ្លាចយួនគេមកស៊ើបដឹង?

មឿន :	គេស៊ើបដឹង គេកាក់វ៉ៃកម្លាំងយើងហ្នឹង ។

បូលី :	អញ្ចឹងកៀកៗគ្នាដែរអញ្ចឹង?

មឿន :	ចា៎ស! កៀកៗគ្នា ខ្ញុំរត់ឡើងភ្នំអាភ្នំខាងកើតតោងវល្លិ៍បេះៗកូននៅក្នុងថ្នក់ ។

បូលី :	តោងឡើងតាមជញ្ជាំងភ្នំ?

មឿន :	ចា៎ស! គេទម្លាក់វល្លិ៍ឲ្យយើងតោងឡើង គេបាញ់បោះបេទូងៗ អត់ត្រូវទេ ។ ដូចគេថាទឹកដោះម្ដាយថ្លៃរស់មកដល់ឥឡូវនេះ ។

បូលី :	ចុះបើរបួតដៃមក មិន?

មឿន :	ខ្លះក៏បែកក្បាលនឹងថ្ម បែកដោយសារថ្មរមៀល ដែលឲ្យជាន់ថ្មគេឲ្យឈានជាន់ ហើយមីនទៀតហ្នឹង ដូចថាដានជើងខ្ញុំជាន់នេះគេឲ្យដើរជាន់តាម អ្នកពីក្រោយដើរតាមៗគ្នា ជាន់មីន ។

បូលី :	មានមីនទៀត?

មឿន :	ចា៎ស! មីនអាផាប់ក៏ផាប់ អារស់នៅសល់ប៉ុន្មានទៅៗ ខ្ញុំរត់កូនៗឡាក់ៗ ស្រាប់តែភឹងៗ មកស្មានតែគ្រាប់ផ្លោងធ្លាក់មក មិនដឹងថាមីនគោន ហើយខ្ញុំកំពុងតែឡើងបណ្ដើតៗថ្ម ស្រាប់តែមីនគោនមកឡើងផោង ក្រាបឡើងញ័រទទ្រើក ស្រាប់តែងើបឡើងគេថាមកទៅទៀតៗ ខ្មោចផាប់នឿល ហ៊ុយ! ខ្ញុំទៅអត់រួចណា៎ ផងឹតមុខឈឹង គេទៅក្តុតៗ ខ្ញុំទៅអត់រួចទេនៅឆ្មេចភ្នែកនឹងឯង ដល់គេចាប់ទាញដៃអូសមកហ្នឹងបានមក ។

បូលី :	ផាប់ច្រើនពេក?

មឿន :	ចា៎ស! វាផាប់នៅផ្លូវ ហើយគេចពីផ្លូវអត់បាន មីនច្រើនពេក ។

បូលី :	បេះសំណាងមីងអត់នៅក្បែរហ្នឹង?

មឿន :	នៅជិតគ្នាដែលហ្នឹង ប៉ុនខ្ញុំក្រាបភ្លឹបអញ្ចឹងទៅ គេដើរមុខប្រហែលជិតសាលានេះឯង គេផាប់នៅត្រឹមសាលា ខ្ញុំនៅនេះដែលភ្នំវាចោទបេះ ខ្ញុំនៅបាតវាបន្តិចទៅ ចាយផុតគេខ្ពស់ ។

បូលី :	អ៎ូ! ដោយសារនៅបាតហ្នឹង?

មឿន ៖ ចា៎ស! ត្រូវថ្មឡើងខ្ទាយថ្ម មីនគោនៗធាក់ ទៅហែងម៉ាចម្រាសហ្នឹងទាំងអស់ ។

បូលី ៖ អ៊ូ! គេដាក់ធាក់?

មឿន ៖ ចា៎ស! គ្នាប្រាប់ថាឲ្យកន្ទុងឲ្យផុតខ្មែរមីងឃើញហើយហ្នឹង ហើយគ្នាស្រី គ្នាស្លៀកសំពត់ផង គេចគ្រាប់ផ្លោងពីលើមកក៏កន្ទុងអត់ផុត កម្លាំងគេកន្ទុងឡើងអស់រាប់រយហើយ នៅកណ្ដាលម៉ាជួរខ្ញុំនឹងឯង ។

បូលី ៖ ស្រីៗ?

មឿន ៖ ចា៎ស! មានស្រីប្រុសៗ ប្ដីប្រពន្ធគេហ្នឹង កូនងាប់ទាំងកូនងាប់ទាំងប្រពន្ធប្ដី ហើយខ្ញុំក្រាបនៅនឹងឯង បានគេទាញដៃមកឲ្យទៅទៀត ខ្ញុំថាងងឹតមុខរកដួល ។

បូលី ៖ ហើយកូននៅណាកូន?

មឿន ៖ កូនខ្ញុំនៅថ្នក់ហ្នឹង ។

បូលី ៖ អញ្ចឹង! យំ?

មឿន ៖ អត់យំទេ ។ ខ្ញុំស្មានតែគ្រាប់ផ្លោង គេថាគោះទៅៗទៀត ទៅឃើញខោចឡើងកៀសននៀលននោគៗ ឈាមឡើងដាបៗខ្ញុំភ័យចង់ ខ្ញុំងងឹតមុខឈឹង ។

បូលី ៖ ប្រហែលប៉ុន្មាននាក់ ។

មឿន ៖ ៥-៦ នាក់ ទាំងកូនតូច ទាំងមនុស្សចាស់ ទាំងប្ដីទាំងប្រពន្ធ ។

បូលី ៖ ចុះមានអ្នកអត់ទាន់ស្លាប់ តែរបួសធ្ងន់ទេ?

មឿន ៖ អ្នករបួសអាខ្លះ អន្ដុយខ្វាក់ភ្នែក គេដឹកដៃទៅៗ ។

បូលី ៖ ដឹកដៃទៅដើរទៅឈឺណាស់ ព្រោះខ្វាក់ភ្នែកទាំងពីរហើយ ។

មឿន ៖ ចា៎ស! ភាគច្រើនងាប់ នៅជិតគ្នាៗហ្នឹង ។ ចុះមីនគោន តែផ្ទុះហើយ មុខអ្នកណាទៅទាំងម៉ាខ្សែហ្នឹង ។

បូលី ៖ ហ៊ឺ! ដូចវេទនាណា៎មីង ។ អញ្ចឹងយើងរត់ចល័តទៅមកៗអញ្ចឹង?

មឿន ៖ ចា៎ស!

បូលី ៖ ស៊ីងច័ន្ទ សែសិប ស៊ីងច័ន្ទៗ ដាំស្លា អូរហាសិបអីអញ្ចឹងទៅ?

មឿន ៖ ចា៎ស! ត្រឹមប៉ុណ្ណឹងឯង វិលចុះវិលឡើង ។

បូលី ៖ គេបាញ់កន្លែងនេះយើងរត់ទៅនោះទៅ?

មឿន ៖ ចា៎ស!

បូលី ៖ គេបាញ់កន្លែងនេះ រត់មកនេះវិញទៅ?

មឿន ៖ ចាស! មកនៅត្រឹមដាំស្វាហ្នឹងឯងបានគេឲ្យមកដីខ្មែរយើងវិញ ហើយបានចុះមកនៅហ្នឹង ជំនាន់អ៊ុន គាក់ ។

បូលី ៖ អ៊ុន គាក់ ចុះមក?

មឿន ៖ ចាស! ហ្នឹងឯងដែលថាជំនាន់ អ៊ុន គាក់ ។

បូលី ៖ អ្នកនេះកើត ៨០ប៉ុន្មាន?

កូន ៖ ខ្ញុំកូនធម៌គាត់ទេ (កូនធម៌របស់មីងមឿន) ។

កូន ៖ ខ្ញុំកើត៧៨ ។

មឿន ៖ ជំនាន់ អ៊ុន គាក់ហ្នឹងគេឲ្យចុះពីដាំស្វាមកនៅនេះជាប់រហូត ទាល់ឥឡូវនេះ មកនេះជាប់រហូតដល់នេះគេផ្លាស់ឲ្យទៅនៅនោះ អ៊ី! ព្រះប្រលាយ ទៅនៅហ្នឹងទៅដល់ពេលនេះគេឲ្យមកនៅនេះវិញ ។

បូលី ៖ ព្រះប្រលាយគេទៅតាមណាមីង?

មឿន ៖ តាមផ្លូវចាស់ហ្នឹងទៅនេះ ទៅតាមក្រោយហ្នឹង ។

បូលី ៖ ចុះអានេះទៅបានទេ ផ្លូវហ្នឹង?

មឿន ៖ ទៅមិនបានទេ គ្មានផ្លូវទេ ឥឡូវសុទ្ធតែព្រៃហើយ ។

បូលី ៖ អញ្ចឹងបើចង់ទៅព្រះប្រលាយទាល់តែបកក្រោយវិញសិន?

មឿន ៖ ចាស!

បូលី ៖ បើបកក្រោយចូលតាមណា?

មឿន ៖ មើល! បកក្រោយទៅចូល ខ្ញុំចង់វង្វេងដែរឥឡូវ ទៅចូលនោះ!ស្ពឺដិនយំអីនោះ!

បូលី ៖ អូ! ទៅចូលទួលគ្រួសនោះវិញ?

មឿន ៖ ចាស! ទៅទួលគ្រួសនោះ ។

បូលី ៖ មិនចូលតាមនេះទេ?

មឿន ៖ តាមនេះដូចព្រៃនេះហើយ ឥឡូវនេះ ។ ដូចខ្ញុំថាឯងមានតែផ្លូវនោះ ផ្លូវថ្មីគេធ្វើដើងភ្នំ ។

បូលី ៖ ត្រពាំងបី?

មឿន ៖ ចាស! ផ្លូវត្រពាំងបីចេះ ផ្លូវទៅព្រះប្រលាយចេះ ហ្នឹងឯងខ្ញុំទៅនៅភូមិចាស់ខ្ញុំឯង ។

បូលី ៖ ផ្លូវនេះមិនយើងទៅអន្លង់វែងវិញ?

មឿន ៖ ចាស!

បូលី ៖ ទៅដល់ជាប់?

មឿន ៖ ចាស!

បូលី ៖ កាត់តាមព្រះប្រលាយ?

មឿន ៖ ព្រះប្រលាយហ្នឹងឯង ប្រលាយថ្មី។

បូលី ៖ អញ្ចឹងម៉េចថាទៅអត់ដល់តាមនេះ?

មឿន ៖ ខ្ញុំថាទៅដល់ ប៉ុនផ្លូវចាស់នេះអត់ទៅដល់ ផ្លូវចាស់នេះវាមានព្រៃខ្លាំងណាស់ អានេះគេទើបតែធ្វើឥឡូវនេះ ឡានយើងបរអត់កើតទេ បានតែបើកគោយន្ត ដល់ផ្លូវគេឥឡូវគេធ្វើដើងភ្នំហ្នឹងទៅដល់ ប៉ុនទៅដល់ឡានជិតជ្រុះក្បាលទេដឹង ។

កូន ៖ ផ្លូវហ្នឹងខ្ញុំធ្លាប់ទៅយប់ម្តងហើយតាស់! ដើរប្រហែលម៉ោង១១យប់ យកបាយទៅឲ្យខ្សែកាលហ្នឹង ទៅបីនាក់ចែ រឹម ទៅយប់ទំរាំដើរដល់ម៉ោងជិត១ហើយ ។

បូលី ៖ ឆ្នាំណា?

កូន ៖ ឥឡូវហ្នឹង ឆ្នាំហ្នឹង ប៉ុន្មានខែនេះ ។

បូលី ៖ ម៉េចបានដើរដល់ម៉ោង១យប់?

កូន ៖ ដើរខ្ញុំចេញពីនេះទៅ ម៉ោង៩ហើយនោះ ។

បូលី ៖ ទៅធ្វើអី?

កូន ៖ យកបាយឲ្យប្តីខ្ញុំ ។

បូលី ៖ អ៊ូ! នៅចាំចម្ការនោះ?

កូន ៖ អត់ទេ! គាត់ចុះពីភ្នំមក ។

បូលី ៖ អ៊ូ! ចុះពីភ្នំណា?

កូន ៖ ភ្នំហ្នឹង! ភ្នំស្រួចដាងគេ ។

បូលី ៖ ហើយឡើងទៅធ្វើអី កាប់ឈើ?

កូន ៖ ទៅរកឈើ ។

បូលី ៖ មានទេឥឡូវ?

កូន ៖ គ្មានទេ!

បូលី ៖ ហើយដល់ពេលមីងចុះមក ចុះតាមណា៎?

មឿន ៖ ចុះមកតាមច្រក ឈូករុនហ្នឹងឯង ។

បូលី ៖ មិនមែនចុះតាមជាំស្រងាំទេ?

មឿន ៖ អត់ទេ!

បូលី ៖ ច្រកឈូករុនហ្នឹង កាលពីសម័យហ្នឹងផ្លូវចុះមកស្រួលទេ?

មឿន ៖ កាលមុនផ្លូវស្រួលតា៎ស គ្មានបាក់គ្មានអី ឥឡូវបាក់បែកអស់ហើយ ។

បូលី ៖ ចោទទេ?

មឿន ៖ អត់សូវចោទទេ គេធ្វើផ្លូវស្រួល អានេះទាបជាងគេ ។

បូលី ៖ ទាបជាងគេ?

មឿន ៖ ចា៎ស!

បូលី ៖ ឡានបើកកើត ពេលហ្នឹង?

មឿន ៖ កាលមុនបើកកើត ឥឡូវបើកអត់កើតទេ ដាច់សាបដាច់អីអស់ហើយ ។

បូលី ៖ ពេលមីងចុះមកហ្នឹង មីងជិះឡាន ឬជិះអី?

មឿន ៖ ដើរ ។

បូលី ៖ ដើរ?

មឿន ៖ ចា៎ស!

បូលី ៖ ច្រើនទេចុះមកហ្នឹង?

មឿន ៖ ច្រើនប្រពន្ធទាហានៗហ្នឹង ខ្លះគេទៅស្រុកគេទៅ ខ្លះនៅ ។

បូលី ៖ ៦១២ មីង?

មឿន ៖ ចា៎ស!

បូលី ៖ ៦១២ហ្នឹងពេលមីងចុះមកដល់ដំបូងមីងនៅម្តុំណា?

មឿន ៖ មិននៅ៦១២ ជាប់រហូតណា៎ មកនៅជាមួយកងតា០៥ ទៀត ។

បូលី ៖ អូ៎! ៨០១?

មឿន ៖ ចា៎ស! ៨០១ ។

បូលី ៖ អញ្ចឹងចេញពី៦១២មក មក៨០១?

មឿន ៖ ចា៎ស! បែកគ្នាអស់ហើយកងចាស់ ។

បូលី ៖ កាលចេញពី១០០២មកហ្នឹង?

មឿន ៖ ចា៎ស! បែកគ្នាហើយ ដល់ហើយមកជាប់នៅជាមួយតា០៥ហ្នឹង ។

បូលី ៖ បាទ! ហើយចុះមកហ្នឹង ចុះមកនៅណា៎?

មឿន ៖ នេះមកនៅអូរនោះ អូរក្រោយនោះ ។

បូលី ៖ ឃុំអីគេហ្នឹង?

មឿន ៖ ឃុំហ្នឹងឯង ។

បូលី ៖ ឃុំទំនប់ដាច់ហ្នឹង?

មឿន ៖ ចា៎ស!

បូលី ៖ មិនមែនព្រះប្រលាយទេ?

មឿន ៖ អត់ទេ!

បូលី ៖ ចុះមកយើងនៅតាមកងពលយើងសិន?

មឿន ៖ ចា៎ស! នៅជាមួយតា០៥ហ្នឹងឯង ។

បូលី ៖ មីងនៅ៨០១?

មឿន ៖ ចា៎សនៅជុំជាមួយគ្នាហ្នឹង ។

បូលី ៖ បាទ! ៨០១ នៅទំនប់ដាច់?

មឿន ៖ ចា៎ស!

បូលី ៖ នៅម្តុំណាមីង នៅម្តុំផ្ទះបងវ័ន្តហ្នឹង?

មឿន ៖ អាវ័ន្តគេនៅកន្លែងរាល់ថ្ងៃ ពួកខ្ញុំនៅនេះ ។

បូលី ៖ នេះហ្នឹង ឥឡូវហ្នឹងគេហៅអីគេ?

មឿន ៖ ទំនប់ដាច់ហ្នឹង ។

បូលី ៖ ទំនប់ដាច់ដែរ?

មឿន ៖ ចា៎ស!

បូលី ៖ ឃុំ ភូមិ អីគេមីង?

មឿន ៖ ភូមិសែនសុខហ្នឹងឯង ។

បូលី ៖ អ៊ូ! នៅសែនសុខ ហ្នឹងដែរទេ?

មឿន ៖ ចា៎ស!

បូលី ៖ អ៊ើ! ទំនប់ដាច់ ៨០១ ។

មឿន ៖ កាលមុនគេអត់ដាក់ភូមិទេ គេដាក់លេខ ។

បូលី ៖ ភូមិមីង ភូមិលេខប៉ុន្មានកាលហ្នឹង?

មឿន ៖ គេហៅ៨៦, ៨១, ៨៥ គេហៅលេខ ខ្ញុំនៅ៨៦ ។

បូលី ៖ ៨៦?

មឿន ៖ ចា៎ស!

បូលី ៖ បាទ! ហើយពេលហ្នឹងយើងរត់ឡើងភ្នំទៀតទេ ឬក៏យើងចុះមកជាអង្គ្រែយ៍ហើយ?

មឿន ៖ ចុះមករហូតអត់មានឡើងទៀតទេ ។

បូលី ៖ អត់មានរត់ឡើងវិញទេ?

មឿន ៖ អ៊ូ! រត់ ចុះមករត់ទៅមួយសារទៀត មួយសារខ្ញុំទម្ងន់មីស្រីនេះ មីពៅហ្នឹងឯង ។

បូលី ៈ តែមួយសារ ឬពីរសារ?

មឿន ៈ តែមួយសារទេ ឈប់រត់រហូតហ្នឹងឯង ។

បូលី ៈ មួយសារហ្នឹងរត់ប្រហែលជាឆ្នាំប៉ុន្មាន?

មឿន ៈ មើល៎! មីយ៉ាទើបតែមួយខែ ពីរខែ ខ្ញុំរត់ឡើងលើភ្នំចាញ់ចង់ផាប់ចង់រស់ រត់ទៅនៅបាន ប៉ុន្មានគេឲ្យចុះមកវិញហ្នឹងឯង ។

បូលី ៈ អាពៅ កើតឆ្នាំប៉ុន្មានអាពៅគេ?

មឿន ៈ ឆ្នាំចរ ។

បូលី ៈ ចរ ៩២?

មឿន ៈ យន្តហោះទម្លាក់ៗនៅភូមិនេះម្តង ។

បូលី ៈ បោះឆ្នោតហើយឬនៅកាលហ្នឹង?

មឿន ៈ បោះមិនដឹង! យន្តហោះមកទម្លាក់ឡើងរត់ ។

បូលី ៈ យន្តហោះខាងណា?

មឿន ៈ ខាងរដ្ឋាភិបាលហ្នឹងឯង ។

បូលី ៈ អញ្ចឹង?

មឿន ៈ ចា៎ស!

បូលី ៈ អញ្ចឹងរត់ហ្នឹងរត់ដោយសារតែយន្តហោះទម្លាក់ទេអញ្ចឹង?

មឿន ៈ ទេ! គេវ៉ៃគ្នាក៏រត់ ប៉ុនគេមកវ៉ៃអាយន្តហោះទម្លាក់ហ្នឹងមួយសារ ខ្ញុំកើតមីងហ្នឹងហើយ ចុះមកវិញហើយកើតមីហ្នឹង យន្តហោះទម្លាក់ក្រោយ ។

បូលី ៈ អ៊ូ! អញ្ចឹងអារត់ហ្នឹង រត់គេវ៉ៃទេ?

មឿន ៈ ចា៎ស! សភាពការណ៍ស្រួលគេជម្លៀសទៅ ។

បូលី ៈ ខាងណាវ៉ៃ?

មឿន ៈ ខាងហ្នឹងឯងគេវ៉ៃ ។

បូលី ៈ ខាងរដ្ឋាភិបាល?

មឿន ៈ ចា៎ស!

បូលី ៈ កាលហ្នឹងបោះឆ្នោតហើយ ឬនៅ?

មឿន ៈ បោះម្តងហើយដឹង ជំនាន់ហ្នឹង ។

បូលី ៈ កាលហ្នឹងមានខាង ហ៊ុនស៊ិនប៉ិច មកវ៉ៃទេកាលហ្នឹង?

មឿន ៈ មិនដឹងខាងណា ខាងណីទេចម្រុះគ្នាអញ្ចឹង ។

បូលី ៖ ដឹងតែមានគេវ៉ៃ រត់ឡើងភ្នំ?
មឿន ៖ ចា៎ស! ដឹងតែរត់ វ៉ៃរត់ៗ ។
បូលី ៖ ដល់រត់ឡើងភ្នំទៅ ផ្ទះសម្បែងយើងមានដុតចោលទេ?
មឿន ៖ អត់ដុតទេ មានទាហានគេនៅការពារហ្នឹងស្រេច ។
បូលី ៖ រត់ឡើងភ្នំហ្នឹង រត់ឡើងតាមណា?
មឿន ៖ ឈូករុនហ្នឹងឯង ។
បូលី ៖ រត់ទៅនៅណាវិញ?
មឿន ៖ ទៅនៅត្រឹមឈូករុន ។
បូលី ៖ ត្រឹមឈូករុនទេណ៎?
មឿន ៖ ចា៎ស!
បូលី ៖ អ៎! នៅលើភ្នំអញ្ចឹង?
មឿន ៖ នៅលើភ្នំ ។
បូលី ៖ ហើយនៅប៉ុន្មានថ្ងៃ?
មឿន ៖ នៅល្មមតែគេវ៉ៃ ល្មមតែគេថាស្រួលហើយគេឲ្យចុះមកវិញ ។
បូលី ៖ ប្រហែលប៉ុន្មានម៉ាអាទិត្យអីទេ?
មឿន ៖ អេ៎ស! មិនមែនម៉ាអាទិត្យទេ មួយខែ ពីរខែ ។
បូលី ៖ អ៊ូ! មួយខែ ពីរខែនោះ?
មឿន ៖ ចា៎ស!
បូលី ៖ ហើយបានយើងចុះមកវិញមក?
មឿន ៖ ចុះមកវិញមក ។
បូលី ៖ ហើយមីងមកនៅនេះឆ្នាំណា?
មឿន ៖ មើល៎! ឆ្នាំទេអ៊ី ចុះមកនៅរហូតឆ្នាំ មិនទាន់ត្រូវរូវគ្នាទេ នៅវ៉ៃគ្នានៅឡើយ ។
បូលី ៖ អត់ទាន់សមាហរណកម្មទេមីង?
មឿន ៖ ទេ! នៅ ។
បូលី ៖ ដែលដូរមកនេះ?
មឿន ៖ ចា៎សនៅ! នៅប្តីខ្ញុំអីនៅហ្នឹង គាត់ចូលទៅៗកម្ទាំងប៉ុន្មាននោះ បានចប់សង្គ្រាមដល់ឥឡូវនេះហ្នឹង ។
បូលី ៖ ចូលទៅដើម្បីដឹកនាំវ៉ៃមកវិញ?

មឿន : ចាស! ខ្ញុំថាខ្ញុំមិនរស់ទេ តាម៉ុកដឹកយកទៅវ៉ៃចោលអស់ហើយ ។

បូលី : គាត់ទៅជាមួយតាកែវ តាជុំអីហ្នឹងអី?

មឿន : ចាស! ពួកតាកែវ តាជុំទៅមុនប៉ុនអត់មានកម្លាំងទេ ។

បូលី : ទៅតែខ្លួនទេ?

មឿន : ចាស! គាត់អត់មានកម្លាំងគាត់ទៅតែគ្រួសារគាត់ ហើយនឹងមេៗប៉ុន្មាននាក់ហ្នឹង ។

បូលី : ហើយពូនេះជាអ្នកដឹកនាំកម្លាំងទៅ?

មឿន : ចាស! សុទ្ធតែកម្លាំងទៅ ។

បូលី : ទៅៗជួបតាជុំនោះ?

មឿន : ចាស!

បូលី : ហើយបានវ៉ៃបកមកវិញ?

មឿន : ចាស! ទៅសុំកម្លាំង ហ៊ុន សែន មកគាត់ហ្នឹងហើយជាអ្នកនាំទៅ ។ មីងខ្ញុំថា បើទៅហើយ មិននៅឲ្យស្ងៀមស្ងាត់ទេ អាគេនេះគរទៅដឹកវ៉ៃចោលប្រពន្ធចង់ងាប់ហើយ មួយថ្ងៃៗគេ ចល័តទៅនេះ ចល័តទៅនោះ ។

បូលី : មិននៅស្ងៀមស្ងាត់ម៉េច.

មឿន : គាត់ចេះតែមកៗសុំកម្លាំងគេ មកវ៉ៃយកប្រពន្ធកូនខ្លាចតាម៉ុក សម្លាប់អស់ហ្នឹង ។

បូលី : ពីណាគេ?

មឿន : តាម៉ុក ហ្នឹងឯង ។

បូលី : ចុះពីណាគេជាអ្នកសុំកម្លាំងគេទៅវ៉ៃ?

មឿន : នេះឪវា ។

បូលី : អ៎!

មឿន : សុំកម្លាំងគេមកឲ្យត្រូវគ្នានោះ គាត់មិនមានប្រពន្ធកូនណាទៅជាមួយខ្ញុំនៅនេះ គាត់នៅនោះ គាត់ចូលទៅ គ្មានប្រាប់ប្រពន្ធឲ្យដឹងទេ គាត់ចូលទៅគាត់ខ្លាចបែកការណ៍ ខ្លាចប្រពន្ធមិន ស្មោះត្រង់ជាមួយគាត់ ខ្លាចខ្ញុំលាក់មិនជិត គ្រាន់តែប្រាប់ខ្ញុំមួយម៉ាត់ថា បើអត់ពីគាត់ទៅ យកប្ដីទៀត? ហើយខ្ញុំថាយកធ្វើអី យើងមានកូនឡើង៥នាក់ហើយ តែប៉ុណ្ណឹង ។ ទៅ បានពីរថ្ងៃ បីថ្ងៃគេអូ មកកោកៗ ឯនេះឲ្យខ្ញុំចុះពីលើផ្ទះមិនឲ្យដេកនៅលើផ្ទះទេ ។

បូលី : ម៉េចអញ្ចឹង?

មឿន : គេយាមរហូត គេខ្លាចប្ដីយើងមកវ៉ៃយក តែខ្ញុំកំសត់ណាស់ ពូអើយខ្ញុំនោះ ។

បូលី : ខាងណាយាម ខាងតាម៉ុក?

មឿន ៖ ខាងតាម៉ុក ហ្នឹងឯង ។

បូលី ៖ គេមកយាមរហូតអញ្ចឹងតែម្តង?

មឿន ៖ ចា៎ស! ខ្ញុំអើយយំ អត់បាយមួយអាទិត្យ ខ្ញុំមិនដែលហូបបាយទេ ។

បូលី ៖ ម៉េចអញ្ចឹង?

មឿន ៖ ចុះខ្ញុំអញ្ចឹងហើយ ខ្ញុំពិបាកចិត្តខ្ញុំនោះ ។ មួយអាទិត្យខ្ញុំមិនដែលស្គាល់បាយទេ ខ្ញុំអង្វរគេថាខ្ញុំឲ្យយកខ្ញុំចុះពីផ្ទះ ឲ្យខ្ញុំនៅផ្ទះហើយប្តីខ្ញុំក្បត់ក៏ក្បត់ទៅ ខ្ញុំអត់ក្បត់ទេ ខ្ញុំនៅហ្នឹងខ្ញុំអាណិតកូនខ្ញុំ ឲ្យខ្ញុំដេកលើផ្ទះទៅ កុំឲ្យខ្ញុំទៅដេកនៅដី គេថាបើឯងហៅប្តីឯងមកវិញហ្នឹងគេឲ្យដេកលើផ្ទះ ។ គេដឹកចេញៗទៅបាត់ទៅ នៅតែផ្ទះទុកចោលហ្នឹង គេអត់ឲ្យយកខោអាវទៅទេ គេឲ្យយកតែ ។

បូលី ៖ គេដឹកយកទៅណា?

មឿន ៖ ដឹកយកទៅដាក់អីកុងប៉ិញនោះ អន្លង់វែង ។

បូលី ៖ អូ៎! អន្លង់វែងនោះ?

មឿន ៖ ចា៎ស! ដឹកយកទៅដាក់កុងប៉ិញ បានបួនដប់ថ្ងៃផ្លាស់មកនៅកន្លែងអូរដឹក សារេវ៉ៃចោលហ្នឹង ប៉ុនគេសារេមិនទាន់ចំណាំពូ ។

បូលី ៖ អ៊ូ! យល់ហើយៗ ។ អញ្ចឹងគេដឹកប្រជាជនណាដែលមានប្តីរត់ចេញទៅ?

មឿន ៖ ចា៎ស! ដឹកចុះដឹកឡើង ខ្ញុំអើយចង់ងាប់ចង់រស់ ។

បូលី ៖ គេដឹកប្រជាជនទាំងអស់ម៉ាភូមិតែម្តង ឬក៏?

មឿន ៖ អត់ទេ! តែភូមិខ្ញុំ តែគ្រួសារខ្ញុំ ហើយនឹងបីគ្រួសារទេ ។

បូលី ៖ តែអ្នកមានប្តីរត់ទៅចុះចូលជាមួយរដ្ឋាភិបាលទេ?

មឿន ៖ ចា៎ស!

បូលី ៖ អញ្ចឹងខ្ញុំ ស្មានតែទូទៅ?

មឿន ៖ ទេ! ខ្ញុំថានៅតែថ្ងៃងាប់ ភ័យចង់ងាប់ចង់រស់ហើយ បានរស់ដល់រាល់ថ្ងៃ ខ្ញុំអរចង់ដាច់ខ្យល់ហើយ ។

បូលី ៖ គេយកទៅដាក់នៅណា៎ កុងប៉ិញ?

មឿន ៖ កុងប៉ិញៗទៅនៅកន្លែងទល់មុខមន្ទីរពេទ្យ នៅខាងលិចផ្លូវ សុទ្ធតែព្រៃមុំត្រង់ហ្នឹង មានផ្ទះណា ។

បូលី ៖ នេះប្រពន្ធតា ប៊ុន ពុត ក៏អញ្ចឹងដែរ ។ ទៅជាមួយគ្នាដែរ ឬអត់?

មឿន ៖ ចាស! ទៅជាមួយគ្នាហ្នឹងឯង ខ្ញុំថាមានតែខ្ញុំទេ ចូលទៅដល់គេហៅខ្ញុំទៅ និយាយពីញាក់ពូអើយ ខ្ញុំថាថ្ងៃណាគេដឹកចូលទៅរដ្ឋាភិបាលក្អក កូនខ្ញុំវាអរវាទះដៃអរអើយអរៗ ហើយម៉ែនេះភ័យចង់ស្លាប់ហើយ ទាហានរដ្ឋាភិបាលគេថា "មក! កាំភ្លើងដែលគេយាមយើងខ្ញុំស្មានតែគេយកទៅវៃចោល" ខ្ញុំហៅកូនយកទៅដាក់ក្នុងអណ្ដូង ខ្ញុំយកទៅទម្លាក់អណ្ដូងអស់ខ្ញុំលោតតាមក្រោយហើយ គេថាកុំធ្វើអីគេធ្វើលេងទេ គេមិនធ្វើបាបទេ គេធ្វើលេងទេ កូនខ្ញុំរួចខ្លួនអរទៅ គេថាតោះទៅទៀត បានអរតែម្ដងឈប់ភ័យហើយ! មុនៗនៅភ័យ ។

បូលី ៖ ពេលដែលពួដឹកនាំកម្លាំងវៃចូលមកហ្នឹង មីងមានរត់ឡើងភ្នំទេ?

មឿន ៖ គ្មានរត់ណា បើគេបញ្ជូនខ្ញុំទៅនោះបាត់ហើយហ្នឹង ។

បូលី ៖ ទៅណាវិញ?

មឿន ៖ ទៅសៀមរាប, អន្លុងវែង ស្គាល់អន្លុងវែងទេ?

បូលី ៖ បាទៗ!

មឿន ៖ ចាស! អន្លុងវែង ទៅណាខេត្តកំពង់ធំ បានមកធ្លាក់ព្រះវិហារ គាត់មកវៃនេះបាត់ ។

បូលី ៖ ពីណាបញ្ជូនទៅ?

មឿន ៖ តាម៉ុក! ខ្ញុំថារឿងខ្ញុំកំសត់ណាស់ ។

បូលី ៖ អ្ហូ! បញ្ជូនទៅបានឆ្ងាយ?

មឿន ៖ បញ្ជូនទៅខាងនោះ ទៅអន្លុងវែង ពីអន្លុងវែងទៅស្អីណាទៀតនោះ ភូមិរមៀត បុកស្បូវ បុកស្អីណានោះហើយបានធ្លាក់ទៅវត្តអន្លុងវែង ។

បូលី ៖ ម៉េចមិនរត់ទៅសៀមរាបតែម្ដងទៅ?

មឿន ៖ ទៅសៀមរាម ណាបើគេបញ្ជូនឲ្យទាហានរដ្ឋាភិបាល ថាឯងមិនយកប្រពន្ធឯងមក អញឈប់ទុកប្រពន្ធឯងហើយ អញបញ្ជូនទៅហើយ ឯងមកយកប្រពន្ធឯងទៅនេះៗអញ្ចឹងគេយកទៅដាក់ត្រង់ហ្នឹងក៏ដើរទៅ ដើរទៅទាហានរដ្ឋាភិបាលមកៗទល់មុខគ្នាហ្នឹង មិនដឹងធ្វើម៉េចពួកខ្ញុំ តែខ្ញុំពុលអាថ្នាំពុលផងចង់ស្លាប់ចង់រស់មួយយប់ហ្នឹង ។

បូលី ៖ ថ្នាំពុលម៉េច?

មឿន ៖ ថ្នាំពុលខ្មែរក្រហមគេដាក់តាមទឹកអណ្ដូងនោះ ស្រេកទឹកក៏ដឹក កូនខ្ញុំចុះពីលើឡានទៅដងមកដឹក ចង់ស្លាប់ចង់រស់ថា មិនរស់ទេមួយយប់ហ្នឹង ។

បូលី ៖ ហើយដល់ពេលជួបជាមួយទាហានរដ្ឋាភិបាលធ្វើយ៉ាងម៉េចទៅ?

មឿន ៖ គេដាក់ទល់មុខគ្នាទៅ គេដាក់ជាពួកឯង មួយសារនោះខាងអាហារហ្នឹងគេត្រូវដែលហ្នឹង គេប្រុងចូលសារភាពដែរហ្នឹង ។

បូលី ៖ អ៊ូ! អាហារគេចខ្លួនដែរទេ?

មឿន ៖ ចាស!

បូលី ៖ មិនមែនអាហាររបស់តាម៉ុក ទេអញ្ចឹង?

មឿន ៖ អាហារតាម៉ុក នៅ ។

បូលី ៖ ផ្ដាច់ខ្លួន?

មឿន ៖ គោលការណ៍គេផ្ដាច់ខ្លួនដែរ ប៉ុន្តែគេអត់ទាន់ ។

បូលី ៖ អញ្ចឹងបានមីងអាចរួចខ្លួននោះ?

មឿន ៖ រួចខ្លួន! គេបញ្ជូនឲ្យទៅវៃចោល១ ប៉ុន្តែមិនបានទៅវៃចោលទេ អាហារហ្នឹងគេប្រុងផ្ដាច់ខ្លួនដែរក៏នាំទៅដាក់ជាមួយរដ្ឋាភិបាល ។

បូលី ៖ ឲ្យចូលហ្នឹងតែម្ដង?

មឿន ៖ ចាស! ឲ្យទៅបណ្ដោយទៅ ។

បូលី ៖ អ៊ូ! បើសិនជាអាហារហ្នឹងស្មោះជាមួយតាម៉ុក មីងត្រូវគេវៃចោល?

មឿន ៖ គេវៃ គេដោះដាក់ព្រៃពីប ទោះពាក់កាំភ្លើងពាក់អីស្រេច ចុះគេឆ្ងល់ ម៉េចបានបញ្ជូនមកអីកូនរង៉ាករង៉ាកច្រើនម្ល៉េះ ។

បូលី ៖ មីងចាំទេ អាហារហ្នឹងពីណាគេ?

មឿន ៖ ខ្ញុំអត់ចាំគេទេ អត់មានចាំណាគេទេ អាហារហ្នឹង ។

បូលី ៖ សុំជួបពូបន្តិច សុំបញ្ជាក់រឿង១០០២បន្តិច អត់ច្បាស់ច្រក១០០២ហ្នឹងនៅមុំណាពូ?

ពូ ៖ ១០០២ ច្រកមុំបី ។

បូលី ៖ មុំបី ១០០១ ។

ពូ ៖ ១០០២ ច្រកព្រះវិហារនេះ មុំព្រះប្រាសាទព្រះវិហារនេះ ។

បូលី ៖ បងបូលីបង្ហាញដែនទី ។ នេះត្រពាំងប្រាសាទ, ប្រាសាទព្រះវិហារ, នេះ១០០១, ១០០៣ នៅមុំនេះ ១០០២ មិននៅចន្លោះហ្នឹង ។

ពូ ៖ នៅចន្លោះហ្នឹង ។

បូលី ៖ ប៉ុន្តែនៅមុំណា?

ពូ ៖ នៅមុំជាប់ផ្លូវអានសេះហ្នឹង នៅមុំផ្លូវអានសេះហ្នឹង ចាប់ពីអានហ្នឹងមកនេះ ចុះឡើង១ ។

បូលី ៖ បាទ! ហ្នឹង១០០២?

ពូ ៖ បាទ! ១០០២ហ្នឹងឯង ។

បូលី ៖ ចាប់ពីអានសេះ មកដល់ព្រះវិហារ?

មឿន ៖ បាទ! ចាប់ពីហ្នឹងមកហើយ ។

បូលី ៖ ហ្នឹងគេហៅម្តុំ១០០២ ហើយ?

ពូ ៖ បាទៗ!

បូលី ៖ ចាប់ពីប្រាសាទព្រះវិហារមកដល់ត្រង់នេះ ១០០៣?

ពូ ៖ ១០០៣ ។

បូលី ៖ ពីអានសេះទៅខាងនេះ ១០០១?

ពូ ៖ បាទ! មុំបីហើយហ្នឹង ។

បូលី ៖ មុំបី ។ អញ្ចឹងមិនមែន១០០២ហ្នឹងមានចំណុចណាមួយ ច្រកណាមួយពូ?

ពូ ៖ នៅច្រកម្តុំ ។

បូលី ៖ មានច្រកគេពូ?

ពូ ៖ មាន ច្រកអានសេះនោះ ។

បូលី ៖ ច្រកអានសេះហ្នឹងតែម្តង?

ពូ ៖ បាទៗ!

បូលី ៖ គេហៅច្រក១០០២ហ្នឹង?

ពូ ៖ បាទៗ!

បូលី ៖ ប៉ុន១០០២ វាស្ថិតពីអានសេះមកដល់?

ពូ ៖ បាទមកដល់ប្រាសាទព្រះវិហារនេះឯង ។

បូលី ៖ ប្រាសាទព្រះវិហារនេះ ហើយដល់ពេលចេញពីប្រាសាទព្រះវិហារនេះមមក១០០៣?

ពូ ៖ បាទ! យើងហៅទៅតាមគេហៅ ខ្ញុំមិនដឹងថា ១០០២, ១០០៣ហ្នឹងយ៉ាងណាទេ ប៉ុនហៅទៅតាមថៃ, អ៊ូស៎! ហៅទៅតាម ប្រាសាទនេះតាមខ្សែបន្ទាត់ហៅថាមុំបី ។

បូលី ៖ ចុះ១០០២ហ្នឹងមានប៉ុន្មានកងពលដែរ?

ពូ ៖ ១០០២យកមកដាក់ហ្នឹងមាន កាលខ្ញុំមកឈរជើងនៅហ្នឹងមានកងពល៦១២, ហើយនឹងហ៎ា កងពលណាខ្លះទេ ចល័តចុះចល័តឡើង ភាគច្រើនមានតែ៦១២ទេ ដែលនៅប្រចាំហ្នឹង ហើយនឹងកងពលណាខ្លះទេ ចល័តចុះចល័តឡើង ភាគច្រើនមានតែ៦១២ទេ ដែលនៅប្រចាំហ្នឹង ។

បូលី ៖ ប្រចាំហ្នឹងតែម្តង?

ពូ ៖ បាទ! កង់តាអឿន ៗ

បូលី ៖ បាទៗ! អនុតាអឿន ពីណាគេ?

ពូ ៖ អនុតាអឿន មាន?

បូលី ៖ បាទ! តាវណ្ណ កុសល យើងនេះ?

ពូ ៖ បាទ! វណ្ណ កុសល មានតាស៊ន់ យើងហ្នឹង ៗ តាស៊ន់ អភិបាលស្រុកហ្នឹង ៗ

បូលី ៖ បាទ! ចុះប្រាសាទព្រះវិហារពេលហ្នឹង ឆ្នាំ៩០ជាងហ្នឹង ខាងយើងកាន់កាប់ ឬខាងរដ្ឋាភិបាលកាន់កាប់?

ពូ ៖ ឆ្នាំ៩៣មក យើងកាន់កាប់ ៗ

បូលី ៖ មុនហ្នឹង?

ពូ ៖ មុនហ្នឹងរដ្ឋាភិបាល ៗ

បូលី ៖ ៨០អីពីណាគេកាន់កាប់?

ពូ ៖ រដ្ឋាភិបាល ៗ

បូលី ៖ អ៊ូ! អញ្ចឹងខាងខ្មែរក្រហមយើងកាន់កាប់ពី៩៣មកទេអញ្ចឹង?

ពូ ៖ បាទ!

បូលី ៖ ចុះ៨១, ៨២អីនោះពូ?

ពូ ៖ ៨១, ៨២ ក៏រដ្ឋាភិបាល ៗ

បូលី ៖ អ៊ូ! យល់ហើយ ៗ ខ្ញុំមានតែប៉ុណ្ណឹងទេមីង ដែលសួរមីង ហើយពូ បាទ! អរគុណច្រើនបានផ្ដល់ព័ត៌មាន ៗ

មឿន ៖ ចាស!

«ចប់»